# រឿងកុលាបប៉ៃលិន

## រឿងកុលាបប៉ៃលិនវគ្គទី១

គ្រាកាលព្រះសុរិយទេវបុត្រ ទ្រង់គង់លើវិមានកែវផលិត ដែលជារថព្រះទីនាំងទឹមដោយសេះអាជានេយ្យ១ពាន់ ទ្រង់បរប្រទក្សិណភ្នំព្រះសិនេរុរាជ តាំងអំពីទិសបូព៌ាយាត្រាសំដៅទៅទិសបស្ចឹម តាមចក្ររាសីនៃសុរិយចក្រវាឡ លុះដល់កំណត់បត់ព្រះរាជរថចូលបាំងជ្រុងមហាបព្វតា រស្មីព្រះសុរិយាក៏ជ្រៀងជ្រែចូលកាន់សន្ធ្យារាត្រី នាវេលានោះជាខាងខ្នើត ១៥ កើត ខែ កត្តិក ឆ្នាំ ច ចត្វាស័ក ព.ស. ២៤៧០ ព្រះចន្ទ្រទេវបុត្រយាងឡើងគង់លើវិមានប្រាក់ ជារាជរថព្រះទីនាំង បរចេញមកពីទិសបូព៌ា ឆ្លុះពន្លឺព័ណ៌ប្រាក់ទៅសព្វផែនពសុធា ព្រះចន្ទ្រាហាក់ដូចជាមៀងមើលមកយ៉ាងស្រស់ញញឹម ឆ្ពោះចំទៅលើដំបូលគេហស្ថានមួយនៅខាងលិចផ្សារស្វាយប៉ោ ដែលជាផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង ។

ឯគេហស្ថាននោះ ជាផ្ទះចាស់ប្រក់ក្បឿងដំបូលពីរជាន់ ជញ្ជាំងក្តារ ក្រាលក្តារ សសរមូល នៅហោជាងមានរូបចម្លាក់ឈើធ្វើជារូបរាហូលេបខែ នៅខាងក្រោមរូបនេះគេឆ្លាក់ជាអក្សរមូលតួធំៗថា **សិរិពង្ស** ជាផ្ទះខ្មែរបែបបុរាណ ដែលនៅសេសសល់ដល់មកសម័យឥឡូវនេះ ។

ក្នុងវេលារាត្រីនោះ ពន្លឺរស្មីនៃដួងចន្ទ្រកំពុងចាំងឆ្លុះចូលមកតាមចន្លោះបង្អួច ហើយមានខ្យល់ត្រជាក់បក់ផាត់ជាយចូលមកយ៉ាងរំភើយ ។ ល្មើយត្រសៀកល្មមត្រជាក់ស្រួល នៅខាងក្នុងគេហស្ថាននោះ មានកូនចង្កៀងប្រេងកាត១ ចងភ្ជួរនឹងជញ្ជាំងក្តារល្មមតែឆ្លុះពន្លឺ ឲ្យមើលមកឃើញបុរសជរាម្នាក់ មានរាងកាយស្គាំងស្គមឥតសាច់ឈាម មានតែស្បែកដណ្តប់ឆ្អឹង ដេកស្តូកស្តឹងនាកណ្តាលល្វែងបន្ទប់ នៅក្បែរខាងបុរសជរានេះ មានក្មេងកំឡោះម្នាក់ មុខមាត់ស្រស់បស់ អង្គុយចាំបំរើថែរក្សាជម្ងឺរបស់បុរសជរា ដោយកិរិយាឫកពាស្រពោនស្រពាប់ស្រងូតស្រង៉ាត់ ឥតមានរីករាយបន្តិចឡើយ ដ្បិតខំអត់ងងុយទ្រាំជម្ងឺរបស់បុរសជរា ដែលត្រូវជាឪពុកបង្កើតរបស់ខ្លួន អស់វេលា៣យប់មកហើយ ។

ឯបុរសដែលមានជម្ងឺជាទម្ងន់ កំពុងដេកស្តូកស្តឹងនៅលើដំណេកនេះឈ្មោះ **ចឹម ត្រកូល សិរីពង្ស** កំពុងតែធ្លាក់ខ្លួនទៅជាចំណីអាហារនៃរោគជរា យូរៗគាត់ដកដង្ហើមធំវែងៗ ហើយគាត់ខំបើកភ្នែកក្រឡេកមើលទៅពាសពេញទាំងល្វែងបន្ទប់ដេក ភ្នែកទាំងគូរបស់គាត់សំឡឹងទៅចំមុខក្មេងកំឡោះម្នាក់ ដែលអង្គុយនៅក្បែរខាងខ្លួនគាត់ ។ ឯក្មេងកំឡោះនេះឈ្មោះ ចៅចិត្រ ជា

កូនបណ្តូលចិត្តរបស់គាត់ ហើយជាអ្នកទទួលវង្សត្រកូល **សិរីពង្ស** តទៅអនាគតផង ទើបគាត់ខំញញឹមទាំងក្រៀមក្រំ ប្រឹងនិយាយដោយសូរសំឡេងញ័រៗថា៖

- ចិត្រ កូនមាសថ្លៃឪពុក ! យប់យន់ណាស់ហើយ មិនទាន់ទៅដេកទេឬ ? ទៅ កូនទៅដេកទៅ។

តាចឹមតឿនបង្ខំឲ្យកូនទៅដេកក្រែងអត់ងងុយទៅជាឈឺចាប់ ។
ថៅចិត្រគ្រវីក្បាលដោយអាការបដិសេធ ព្រមទាំងមានទឹកមុខប្រកបដោយចិត្តអាណិតអាសូរបិតា ទើបនិយាយជំរាបទៅវិញថា៖

- ខ្ញុំបាទមិនទាន់ងងុយទេ លោកឪពុក ! ប្រហែលជាលោកឪពុកមិនទាន់ពីសាថ្នាំយោងកម្លាំងទេដឹង ? លោកគ្រូពេទ្យបានផ្តាំខ្ញុំបាទថា សូមឲ្យលោកឪពុកពីសាកុំខាន ។
- ថ្នាំឬ កូន !

តាចឹមនិយាយឮតែក្នុងបំពង់ក ទំនងចំអកឲ្យថ្នាំនោះ ព្រោះជាថ្នាំគាត់ដឹងថា ឥតមានគុណវិសេសអ្វីបន្តិចឡើយ ហើយគាត់និយាយថា៖

- ឪ ! កូនអើយ ថ្នាំនេះឪពុកបានផឹកមកច្រើនលើកហើយ មិនឃើញមានគុណវិសេសអ្វីដែលអាចជួយបន្ធូរបន្ថយជម្ងឺឲ្យបានស្រាកស្រាន្តសោះឡើយ រោគចំពូកនេះឪពុកស្គាល់ច្បាស់ថាជារោគប្រចាំកាយ **រក្សាក៏ស្លាប់ មិនរក្សាក៏ស្លាប់** ឫទ្ធិអំណាចរបស់ថ្នាំក្នុងខណៈនេះ មិនវិសេសជាងទឹកទន្លេទេ កូន !

ថៅចិត្រមិនទាន់បាននិយាយតបទៅឪពុកវិញ ស្រាប់តែលេចបុរសកណ្តាលអាយុម្នាក់ដើរចូលមកក្នុងបន្ទប់ ហើយដាក់គូថអង្គុយក្បែរខាងអ្នកជម្ងឺ ហើយសួរថា៖

- ម៉េចទៅតាថ្ងៃនេះ អាការៈរោគបានធូរស្បើយខ្លះទេ ?

- ឱ ! ពុទ្ធោ ពុទ្ធោ !

តាចឹមលាន់មាត់ឡើង កាលបានឮលោកគ្រូពេទ្យសួរខ្លួនដូច្នោះ ហើយគាត់និយាយតទៅទៀតថា៖

- ឱ ! លោកគ្រូអើយ វេលានេះ ភ្នែកខ្ញុំបាទស្រែស្រវាំងងងឹតអស់ហើយ សូមអត់ទោសចុះ ខ្ញុំបាទមិនដឹងជាលោកគ្រូអង្គុយនៅត្រង់ណាទេ។

ឯចៅចិត្រកាលបើបានឮសំដីឪពុកនិយាយត្អូញត្អែរដូច្នោះ ទឹកភ្នែកក៏ហៀរហូរសស្រាក់ ដោយចិត្តអាណិតឪពុកពន់ពេក ហើយក៏សំឡឹងមើលគ្រូពេទ្យ និយាយអង្វរករសុំឲ្យជួយស្រោចស្រង់សង្គ្រោះបិតាឲ្យមានជីវិត តែគ្រូពេទ្យដែលស្ទាត់ជំនាញក្នុងវិធីមើលជម្ងឺ ក៏គ្រវីក្បាលដោយអស់សង្ឃឹម ខ្សឹបប្រាប់ជិតត្រចៀកចៅចិត្រថា៖

- ឆ្លងមិនផុតអំពីយប់នេះទេ។

តាចឹមនិយាយមួយៗ ទាំងហាត់ដង្ហក់បបូរមាត់សស្លាំង ញ័រចំប្រប់ខំនិយាយទៀតថា៖

- ខ្ញុំបាទគង់មិនមានជីវិតរស់នៅ ទាល់តែបានឃើញពន្លឺព្រះអាទិត្យក្នុងព្រឹកស្អែកនេះទៀតទេ។ ខ្ញុំបាទយល់ថា មិនមែនជាការចំឡែកខុសធម្មតាទេ ព្រោះមរណៈធម៌ជាសភាវៈទៀងទាត់ ដែលមនុស្សសត្វទូទៅត្រូវតែទទួលយកនឹងចៀសវាងឲ្យផុតពុំបានឡើយ ឯវិញ្ញាណនឹងកាយខ្លួនខ្ញុំបាទ ឥតមានស្រណោះអាឡោះអាល័យប៉ុន្មានទេ ស្លាប់ហើយត្រូវទៅកើតជាអ្វីក៏តាមយថាកម្មចុះ។

ហើយបែរទៅនិយាយផ្ដែផ្ដាំថា៖

- ចិត្រ កូនសំឡាញ់មាសឪពុក ! កាលបើឪពុកអស់បុណ្យទៅហើយជីវិតអ្នកមុខជាសាត់អណ្ដែតឥតបង្គោល ជាបង្អែកដូចជាសំណាត់ដែលអណ្ដែតក្នុងទន្លេដូច្នោះ។

ឯចៅចិត្រអួលដើមកនិយាយអ្វីមិនរួចសោះ មានតែទឹកភ្នែកហូរសស្រាក់ឱនមុខជ្រប់ក្រាបចុះជិតជើងឪពុក ។ ចំណែកខាងគ្រូពេទ្យ ក៏ងាកមុខបែរទៅខាងបង្អួច ស្ទើរតែទ្រាំទប់ទឹកភ្នែកពុំបានដែរ ។
តាចឹមនិយាយផ្ដាំទាំងហាត់ថា៖

- នែចិត្រ កូនសំឡាញ់ឪពុក ! កាលបើឪពុកស្លាប់ទៅហើយ ចូរបាចាំបណ្ដាំឪពុកទុកចុះថា ធម្មជាតិគ្រប់យ៉ាងក្នុងលោកនេះ ដែលមនុស្សលោកសំគាល់ថា ជាការរុងរឿងថ្លៃថ្លានោះ គឺការតាំងខ្លួនឲ្យបានស្ដុកស្ដម្ភដោយទ្រព្យសម្បត្តិ ឯការដែលរស់នៅគោកយ៉ាកនោះ អ្នកផងទាំងពួងគេមិនយកភ្នែកមើលទេ ការរស់បែបនេះមិនមែននាំឲ្យបានសុខ

សប្បាយទេ ប៉ុន្តែពេលនេះកូនអើយ ! ឪពុកនឹងប្រាប់អ្នកឲ្យធ្វើដូចម្ដេច ទើបបានសេចក្ដីចំរើននោះពុំបានទេ សុំឲ្យគ្រាន់តែរលឹកដល់ពុទ្ធភាសិតមួយបទថា**អត្តា ហិ អត្តនោ នាថោ** ខ្លួនត្រូវទីពឹងរបស់ខ្លួន ប៉ុណ្ណោះឲ្យរឿយៗចុះ។

ឯគ្រូពេទ្យនិយាយជ្រែកក្នុងខណៈនោះថា៖

- តាកុំអាលអស់សង្ឃឹមរហ័សពេក រោគរបស់តាដែលធ្ងន់ដូច្នេះក៏មិនទាន់ជាអ្វីទេ នៅមានសង្ឃឹមនឹងសះជាឡើងវិញបាន។

តាចឹមបង្អើនឲ្យគ្រូពេទ្យថា៖

- សះជាឬ ? លោកគ្រូ គ្មានផ្លូវសះជាឡើងវិញជាប្រាកដ មានតែផ្លូវស្លាប់មួយមុខក្នុងព្រឹកស្អែក ឬយប់នេះ ឬ ឥឡូវនេះ ក្នុងពេលណាមួយជាមិនខាន។

តាចឹមឈប់និយាយមួយស្របក់ ហើយចាប់និយាយតទៅទៀតថា៖

- នែ ! ចិត្រកូនសំឡាញ់ឪពុក ឪពុកទីទាល់ក្រណាស់ គ្មានកេរ្តិ៍មតិកបន្តិចបន្តួចបំរុងទុកឲ្យកូនឡើយ ដល់ឪពុកស្លាប់ទៅមានតែសពនឹងពាក្យបណ្ដាំប៉ុណ្ណោះទុកឲ្យកូន ឯវិញ្ញាណក្ខន្ធរបស់ឪពុក ដែលនឹងបានទទួលសេចក្ដីសុខក្សេមក្សាន្តក្នុងលោកខាងមុខនោះ លុះតែកូនប្រតិបត្តិតាមបណ្ដាំរបស់ឪពុកទាំងប៉ុន្មានម៉ាត់នេះ ដែលជាបណ្ដាំចុងក្រោយបំផុតរបស់បិតា មួយទៀត វិជ្ជាដែលឪពុកទុកដាក់ឲ្យកូនខំរៀនសូត្រ ដរាបទាល់តែប្រឡងជាប់សញ្ញាប័ត្រនោះទុកជាមតិកមានតម្លៃមួយ ឱ ! តាំងពីថ្ងៃនេះទៅហើយ ឪពុកអស់បានជួយទំនុកបំរុងកូនតទៅទៀតហើយ។

ចៅចិត្រ កាលបើបានស្ដាប់ពាក្យបណ្ដាំរបស់ឪពុកចប់សព្វគ្រប់ហើយ ក៏ស្រក់ទឹកភ្នែកច្រោកៗ ដោយមានចិត្តអាល័យនឹងអាណិតឪពុកជាទីបំផុត ឱនក្បាលទៀបជើងឪពុក ហើយខំនិយាយទាំងខ្សឹកខ្សួលជំរាបឪពុកថា៖

- លោកឪពុក ! បណ្ដាំគ្រប់ៗម៉ាត់ខ្ញុំបាទនឹងកត់ត្រាចាំទុកក្នុងចិត្ត ខិតខំប្រតិបត្តិតាមបណ្ដាំគ្រប់ប្រការ សូមលោកឪពុកកុំបីព្រួយបារម្ភឡើយ ខ្ញុំបាទមានជីវិតរស់នៅដរាបណា នឹងខំតាំងខ្លួនប្រាណដំកល់ដំកើងវង្សត្រកូលឲ្យបានចំរើនដរាបនោះ។

តអំពីពេលនោះ តាចឹមមានអាការដង្ហក់កាន់តែញឹកញាប់ខ្លាំងឡើង មានអាការក្រវល់ក្រវាយ ទំនងស្លឈាម ហើយទន់ពាប់ទៅរាល់ៗគ្រាមរណសង្គ្រាម កំពុងទន្ទ្រានចូលមកជិតអ្នកជម្ងឺគ្រប់ៗដង្ហើម ទើបគាត់ខំប្រឹងនិយាយទៅរកគ្រូពេទ្យ ដែលមានមេត្តាចិត្តចំពោះខ្លួនដោយសូរសំឡេងខ្សាវៗជាទំនងសេចក្តី ថា៖

- ទានប្រោសលោកគ្រូ ! ខ្ញុំបាទនឹងដាច់ខ្យល់ស្លាប់ក្នុងពីរ បីនាទីនេះហើយ សូមអរព្រះគុណនឹងសូមជូនបុណ្យលោកគ្រូដែលមានព្រះគុណលើខ្លួន ខ្ញុំបាទជាអនេក ដោយបានខំថែទាំរក្សាទាំងបង់ខាតថ្លៃថ្នាំជាច្រើនផង ហើយមិនមានគិតថ្លៃរក្សា និងថ្លៃថ្នាំបន្តិចឡើយ ខ្ញុំបាទឥតមានអ្វីតបស្នងសងគុណលោកគ្រូទេ ឱ ! ព្រះគុណអើយ ត្រចៀកខ្ញុំបាទលែងឮហើយ ឱ ! ចិត្រកូន ! ពុទ្ធោ អរហំ ! ។

ថៅចិត្រឱបឪពុកជាប់ ហាក់ដូចជាមិនព្រមឲ្យវិញ្ញាណក្ខន្ធរបស់តាចឹមរត់ចេញពីរាងកាយទៅបាន តែបើទុកជាថៅចិត្រខំប្រឹងទប់ទល់យ៉ាងណា ក៏គង់តែមិនសំរេចដូចបំណង ព្រោះ ជាតិ ជរា ព្យាធិ មរណៈ (កើត ចាស់ ឈឺ ស្លាប់ ) ជាមតិករបស់សត្វលោក ឥតមានសត្វណាមួយគេចវេះចៀសវាងឲ្យរួចផុតទៅបានឡើយ អម្បាលដូចយ៉ាងព្រះអរហំសម្មាសម្ពុទ្ធម៉េចក៏គង់តែស្តេចចូល បរិនិព្វានមិនខាន ។

នៅទីបំផុតនេះ តាចឹមក៏ធ្លាក់ខ្លួនទៅជាចំណីអាហារមច្ចុរាជ គឺដាច់ខ្យល់ផុតដង្ហើមក្នុងកណ្តាប់ដៃរបស់ថៅចិត្រជាកូន តាចឹមក៏ទទួលមរណភាព ក្នុងខណៈដែលដួងចន្ទ្រអស្តង្គបាត់ពន្លឺរស្មី ព្រមជាមួយគ្នាក្នុងគ្រានោះឯង ។

កាលបានចាត់ចែងធ្វើបុណ្យបូជាសពរួចស្រេចហើយ ទើបថៅចិត្រដឹងខ្លួនច្បាស់លាស់ថា៖

- ឱ ! ខ្លួនអញអើយ កណ្តែងកណ្តោចខ្លោចផ្សាតែម្នាក់ឯង ហើយនឹងងាករេទៅពឹងបងប្អូនញាតិសាច់សាលោហិតជិតខាងឯណាក៏គ្មាន ល្ហើយចុះត្រូវតែតស៊ូនឹងសេចក្តីទុក្ខលំបាកគ្រប់យ៉ាងចុះ ធ្វើម្តេចកើតមកជាប្រុសកំព្រាម្តាយអាពុក សមដូចជាប្រសាសន៍លោកឪពុកផ្តាំទុកថា **ចិត្រកូន! កាលបើអស់បុណ្យអំពីឪពុកហើយ ជីវិតរបស់អ្នកដូចសំណាត់ឈើដែលអណ្តែតក្នុងកណ្តាលទន្លេដូច្នោះ** ។

ថៅចិត្រក៏គិតឃើញថា ពិភពលោកទាំងមូលនេះ ធំទូលាយស្រួលសប្បាយមែនសម្រាប់អ្នកដទៃៗតែបែរទៅជាទីតូចចង្អៀត លំបាកពន់ពេក ចំពោះខ្លួនអាត្មាអញដែលកំព្រាម្តាយឪពុក នឹងបងប្អូនញាតិសាលោហិត នឹងងាកមុខទៅជ្រកកោនពឹងពាក់អ្នកឯណា ក៏គេឥតត្រូវការសោះ

ព្រោះមនុស្សទីទាល់ក្រលំបាកដូចជាអាត្មាអញនេះ គេមិនត្រូវការសេពគប់រាប់រកឡើយ ទុកជាសុំការគេធ្វើ ក៏ឥតមាននរណាជួយសង្គ្រោះរកការងារឲ្យធ្វើបានឡើយ ឱ ! ខ្លួនអាត្មាអញអើយ កើតមកក្នុងលោកនេះលំបាកអ្វីក៏សែនលំបាកប្លែកជាងគេម្ល៉េះ តែថាកើតមកជាអង្គបុរសហើយ មិនត្រូវខ្លាចសេចក្ដីទុក្ខព្រួយលំបាកទេ តោងតែតស៊ូនឹងសេចក្ដីទុក្ខព្រួយលំបាកអស់នេះឲ្យឃើញស ខ្មៅ ទៅចុះ ។

ចៅចិត្រកំពុងតែឈរជញ្ជឹងរំពឹងគិត រកការធ្វើតែម្នាក់ឯងយ៉ាងស្ងាត់ៗ នៅចំរៀងខាងមុខផ្ទះ ក៏ងើបមើលទៅលើឃើញព្រះចន្ទអណ្ដែតត្រសៃតនៅកណ្ដាលពពក បញ្ចាំងពន្លឺរស្មីឆ្លុះទៅសព្វទីបរិវេណ មានខ្យល់បក់ផាត់មកយ៉ាងត្រជាក់ស្រេង ឮសូរសំឡេងព្រះសង្ឃសូត្រធម៌នៅវត្តព្រះពិភិធារាមយ៉ាងច្បាស់លាស់ អណ្ដែតលឿនលយមកតាមបណ្ដោយខ្យល់ លុះចៅចិត្របានឮសូរសព្ទព្រះសង្ឃសូត្រធម៌នោះ ក៏ជាហេតុនាំផ្ដួចឲ្យនឹករលឹកដល់ឪពុក ដែលទើបទទួលអនិច្ចកម្មទៅថ្មីៗមិនដឹងបើនឹងងាករបែរមុខទៅពឹង ពាក់អ្នកឯណា ហើយក៏បែរមុខមើលទៅក្នុងបន្ទប់ ឃើញមានពន្លឺចង្កៀងភ្លឺផ្លុងៗ នៅទីនោះហើយដែលឪពុកធ្លាប់មូរថ្នាំស្លឹកសង្កែពីសាជានិច្ច តែឥឡូវនេះមានតែចៅចិត្រម្នាក់ឯង ចៅចិត្រគិតអាណិតខ្លួនណាស់ ទឹកនេត្រាក៏ហូរចេញមកសស្រាក់ដោយឥតដឹងខ្លួន ។

ខណៈនោះ ចៅចិត្រក្រឡេកមើលទៅខាងមុខ ស្រាប់តែឃើញមនុស្សម្នាក់ស្លៀកពាក់សដើរចូលមក ទើបចៅចិត្រក្រោកឡើងស្រែកសួរទៅថា៖

- នរណា នុ៎ះ ?
- គ្នាឯងទេ ចៅចិត្រឬអីហ្នឹង ?

បុរសនោះសួរមកវិញ ។

ចៅចិត្រនឹកស្មានថាប្រហែលគ្រូពេទ្យ ទើបស្រែកអញ្ជើញថា៖

- សូមអញ្ជើញលោកគ្រូ ។

គ្រូពេទ្យក៏ឈានជើងឡើងជណ្ដើរទៅលើផ្ទះ ហើយដាក់គូថអង្គុយលើកៅអី តាមសេចក្ដីអញ្ជើញរបស់ម្ចាស់ផ្ទះ ។

- សុខសប្បាយជាទេឬចៅចិត្រ ?

គ្រូពេទ្យសួរដោយមេត្រីចិត្ត ។

ថៅចិត្រតបថា៖

- ទានប្រោស ចំណែកខាងរាងកាយសុខសប្បាយជាទេ ប៉ុន្តែចំណែកចិត្តរងកម្មជាបំផុត ឥតសប្បាយមួយពេលឡើយតាំងអំពីលោកឪពុកអនិច្ចកម្មទៅ វិញ្ញាណខ្ញុំបាទនេះហាក់ដូចជាងងឹតឈឹងពុំដឹងអ្វីឡើយ ។

គ្រូពេទ្យងក់ក្បាលទំនងជឿតាមសំដីថៅចិត្រ ទើបសួរថែមទៀតថា៖

- ចុះសព្វថ្ងៃនេះ បានធ្វើការនៅកន្លែងណាហើយឬនៅឡើយទេ ?

ថៅចិត្រនិយាយសើចសោះកក្រោះថា៖

- ទាន ប្រោស ! នៅទីនេះ ខ្ញុំបាទរកការធ្វើមិនទាន់បានទេ ការងារគ្រប់ផ្នែកហាក់ដូចជាខ្ពស់ជាងចំណេះរបស់ខ្ញុំបាទ ដែលបានខំរៀនសូត្រមកដូចជាច្រើនណាស់ តែហាក់ដូចគ្រាន់ប្រើការបានត្រឹមតែមើលសំបុត្រស្នាមបន្តិច បន្តួច មើលឈ្មោះហាងផ្សេងៗនឹងមើលប្រូក្រាមតាមរោងកុន ល្ខោន ប៉ុណ្ណោះ ។

គ្រូពេទ្យនិយាយដោយសេចក្ដីអាណិតយ៉ាងស្មោះត្រង់ថា៖

- ខ្ញុំក៏នឹកអាសូរអ្នកច្រើនណាស់ដែរ ! ចិត្រ!

ហើយនិយាយទូន្មានថា៖

- ខ្លួនអ្នកជាកូនប្រុស ត្រូវតទល់នឹងវិស័យលោកិយទៅមុខទៀតច្រើនណាស់ បង្អង់ឲ្យខ្ញុំគិតពីរ បី នាទីមើល ក្រែងខ្ញុំគិតរកឧបាយជួយសង្គ្រោះខ្លួនអ្នកឯងបានខ្លះ។

ថៅចិត្រនៅតែស្ងៀម ។ គ្រូពេទ្យជញ្ជឹងគិតមួយស្របក់ ក៏ញញឹមលាន់មាត់ចេញសំដីថា៖

- នឹកឃើញហើយៗ ! ខ្ញុំមានឪពុកមាម្នាក់ ជាអ្នកស្តុកស្តម្ភគ្រាន់បើ មើលទៅបើលោកជួយធុរៈ មុខជាអ្នកឯងបានការធ្វើមិនខាន តែតោងនឿយហត់បន្តិចមុនដំបូង ។

ថៅចិត្រញញឹមញញែមហើយជំរាបទៅគ្រូពេទ្យថា៖

- ខ្ញុំបានទទួលអត់ធន់សេចក្ដីលំបាកគ្រប់យ៉ាងទាំងអស់ សុំឲ្យមានតែការធ្វើនឹងគេចុះ គ្រាន់នឹងបានចិញ្ចឹមជីវិត កុំឲ្យមានពាក្យគេដំនៀលប៉ុណ្ណោះ ទុកជាជីកដី លីសែង រែក ពុនយ៉ាងណាក៏ដោយ ខ្ញុំបាទក៏ស្ម័គ្រធ្វើទាំងអស់។

គ្រូពេទ្យមានទឹកមុខរីករាយ ដោយសេចក្ដីពេញចិត្តហើយថា៖

- ខ្ញុំគិតជានិច្ចថា អ្នកឯងជាកូនប្រុសអាចទទួលធ្វើការគ្រប់ចំពូកបាន អធ្យាស្រ័យអ្នកឯង គួរសរសើរណាស់ ប៉ុន្តែថៅចិត្រ ! ការដែលអ្នកឯងត្រូវធ្វើនោះ មិនមែននៅក្នុងទីនេះទេ គឺនៅឯស្រុកបប៉ៃលិន ឯណោះ។
- បប៉ៃលិន ឬទានប្រោស !

ថៅចិត្រឆ្លើយផ្ទួនពាក្យ បាត់ទឹកមុខញញឹមរីករាយមួយរំពេច ហើយនិយាយត្អូញត្អែរថា៖

- ទានប្រោស គេថាស្រុកនោះចាញ់ណាស់ មានតែពួកភូមាកុឡា ទើបនៅទ្រាំរកស៊ីក្នុងទី នោះបាន ខ្ញុំបាទនឹកក្រែងតែទ្រាំទ្រទឹកដីអាកាសនៅទីនោះមិនបានទេ ដឹង?

គ្រូពេទ្យទូន្មានថា៖

- អ្នកឯងនិយាយដូច្នេះក៏ត្រូវដែរ ប៉ុន្តែអ្នកដែលទៅហើយឈឺចាញ់នៅទីនោះ ច្រើនធ្វេស ប្រហែសមិនចេះរក្សាខ្លួនឲ្យផុតពីជម្ងឺគ្រុនចាញ់ ចុះចំណែកអ្នកឯងក៏បានរៀនសូត្រចេះ ក្បួនពេទ្យមកខ្លះ ក៏ល្មមនឹងការពារខ្លួនបាន មួយវិញទៀតជម្ងឺគ្រុនចាញ់នេះ មិនចំពោះ តែជាតិយើងទេ ទុកជាជាតិណាក៏ដោយ ធ្វើទាស់ទំនងហើយ មុខជាឈឺចាប់ដូចគ្នាទាំង អស់។

គ្រូពេទ្យនិយាយទូន្មានថៅចិត្រឲ្យមានៈក្លាហានឡើង ហើយពោលតទៅទៀតថា៖

- ឯឪពុកមាខ្ញុំនោះ ពីដើមធ្វើជាមន្ត្រីមួយ ហៅតាមបណ្ដាសក្តិថា **ហ្លួងរតនសម្បត្តិ** វេលា នេះអាយុលោកហាសិបប្លាយឆ្នាំហើយ លោកមានអធ្យាស្រ័យល្អ ពួកកុឡាភូមានៅទី នោះ រាប់អានលោកណាស់ កាលពីពីរ បី អាទិត្យមុននេះ លោកមានសំបុត្រមួយច្បាប់ មកដល់ខ្ញុំ សុំឲ្យរើសរកមនុស្សម្នាក់ទៅធ្វើការលោក ចំពោះរូបអ្នកឯងមួយនេះខ្ញុំទុកចិត្ត ណាស់ ដ្បិតការជីកត្បូងនិល គេត្រូវការតែមនុស្សសុចរិតស្មោះត្រង់។

ថៅចិត្រនិយាយថា៖

- ការនេះជាការថ្មោងថ្មី ក្នុងជីវិតរបស់ខ្ញុំបាទ។

គ្រូពេទ្យថា៖

- គ្រាន់បើជាងនៅទំនេរ មិនទាន់មានការអ្វីធ្វើមែនទេ ? បើព្រមទទួលខ្ញុំនឹងចាត់បញ្ជូនអ្នកឯងនៅវេលាឆាប់ៗនេះ ដោយខ្ញុំមានសេចក្ដីសង្ឃឹមទុកចិត្តថា អ្នកឯងនឹងធ្វើការម៉ឺងម៉ាត់ជាទីពេញចិត្តគេមិនខាន។

ថៅចិត្រលើកដៃសំពះ ហើយក្រាបចុះដោយសេចក្ដីគោរពចំពោះគ្រូពេទ្យ លោកក៏សរសេរសំបុត្រ១ច្បាប់ឲ្យថៅចិត្រ ហើយលាចុះដើរទៅពីផ្ទះនោះទៅ៕

# រឿងកុលាបប៉ៃលិនវគ្គទី២

លុះថៅចិត្របានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់វ៉ាលីសផ្ដៅ នឹងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រះដេកសម្រាកដោយសេចក្ដីត្រេកអរដ៏លើសលប់ក្នុងយប់នោះស្ទើរតែដេកមិនលក់ទាល់ភ្លឺ ។ ដល់ម៉ោង៥ជិតភ្លឺ នាឡិកាឯផ្សារវិលវាយឮសូរម៉ឹងៗយ៉ាងច្បាស់លាស់រហូតដល់ផ្ទះថៅចិត្រៗ ក្រោកឡើងលុបលាងមុខមាត់រួច ក៏ស្លៀកពាក់សំលៀកបំពាក់ យួរវ៉ាលីសចុះពីផ្ទះដើរសំដៅទៅផ្សារវិល បំរុងនឹងទៅឡើងរថយន្តដែលដើរផ្លូវបាត់ដំបង - បប៉ៃលិន ។ ថៅចិត្រទិញសំបុត្រថ្លៃកន្លែងរួចស្រេចហើយ ក៏អង្គុយចាំដរាបដល់ពេលរថយន្តចេញពីទីផ្សារក្រុងបាត់ដំបងទៅ វេលាម៉ោង ៦ នឹង ១៥ នាទី រថយន្តក៏បើកចេញសំដៅទៅទិសខាងត្បូង ដល់ទៅផ្សារភាសុីស្រាក៏បត់ត្រង់ទៅឯលិចតាមផ្លូវបប៉ៃលិន ថៅចិត្រអង្គុយមើលភូមិប្រទេសសងខាងមាគ៌ានោះ មុខគួរឲ្យស្រងេះស្រងោចអណ្ដែតអណ្ដូងក្នុងចិត្តជាចំឡែកណាស់ នឹកដល់ឪពុកដែលទើបអនិច្ចកម្មទៅថ្មីៗ កាលណាទឹកភ្នែកក៏ជោរជន់ចេញមកឯង តែខំទប់ទល់មិនឲ្យទឹកភ្នែកស្រក់ចុះទាល់តែបាន ដើម្បីការពារកុំឲ្យអ្នកជិះរថយន្តជាមួយគ្នា មានសេចក្ដីសង្ស័យមន្ទិលមកលើខ្លួន ហើយបន្លំនិយាយសើចលេងកំសាន្ត ជាមួយនឹងអ្នកជិះទាំងអស់គ្នាទៅ ។

ឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិន មិនសូវឆ្ងាយប៉ុន្មានពីក្រុងបាត់ដំបងក៏ពិតមែន តែជាផ្លូវលំបាកបន្តិច ដ្បិតត្រូវបររថយន្តឡើងកាត់ភ្នំ នឹងសសៀរតាមជើងភ្នំខ្ពស់ឡើងៗ ហើយតោងបរបត់បែនដូចអន្ទង់អាំង ដរាបដល់ស្រុកបប៉ៃលិន ទុកជាបង្ខំយ៉ាងណាក៏គង់តែរថយន្តរត់មិនលឿនរហ័សដូចផ្លូវរាបទេ ។ ថៅចិត្រក្រឡេកមើលភូមិប្រទេសតាមសងខាងផ្លូវ សឹងដេរដាសទៅដោយស្រែចម្ការច្បារដំណាំ និងភូមិស្រុកដោយអន្លើៗ ឃ្លាតឆ្ងាយដាច់ពីគ្នា លុះជិតទៅដល់បប៉ៃលិន ក៏ឃើញតែព្រៃព្រឹក្សា លតាវល្លិនឹងភ្នំតូច ធំច្រើនអនេក ព្រមទាំងសត្វបក្សាបក្សីនិងសត្វដើរដី ក៏មានកុះករណែនណាន់នៅតាមដងព្រៃព្រឹក្សាអស់នោះ ។ ថៅចិត្របានឃើញសព្វសត្វអស់នោះ ក៏កើតមានចិត្តសង្វេគនឹករលឹកដល់ឪពុកកាន់តែខ្លាំងឡើងៗ ស្ទើរតែទប់ទល់ទឹកភ្នែកពុំបាន ។

លុះដល់រថយន្តបរបើកកាត់ព្រៃភ្នំក្រំថ្មជាច្រើនអន្លើ វេលាម៉ោង១១ ថ្ងៃត្រង់ រថយន្តក៏បានទៅដល់ទីផ្សារបប៉ៃលិនដោយស្រួល ។ ថៅចិត្រចុះពីរថយន្តដើរទៅសុីបសួររកផ្ទះហ្លួងរតនសម្បត្តិ ។ មានភូមាម្នាក់នៅទីផ្សារនោះចង្អុលប្រាប់ថា ផ្ទះហ្លួងរតនសម្បត្តិនៅឯណោះ ចម្ងាយពីទីផ្សារនេះទៅប្រហែល៥០០ ម៉ែត្រ ក្បែរមាត់ផ្លូវខាងជើង នៅក្លោងទ្វារផ្ទះនោះ មានសរសេរ

យីហោថា **ផ្ទះហ្លួងរតនសម្បត្តិ** អញ្ជើញទៅចុះគង់នឹងឃើញមិនខាន ។ ថៅចិត្រក៏ចេញដើរទៅតាមពាក្យភូមានោះ ហើយទៅឈររេរានៅមុខផ្ទះដូចមានយីហោខាងលើនេះ មួយស្របក់មានកម្មករម្នាក់ ចេញមកពីក្នុងភូមិនោះសួរថា៖

- អញ្ជើញមករកអ្នកណា ?

ថៅចិត្រភ្ញាក់ព្រើត ព្រោះពេលនោះកំពុងឈរមើលភូមិប្រទេសយ៉ាងភ្លើតភ្លើន ស្រាប់តែក្រឡេកមកឃើញបុរសខ្មៅម្នាក់ ឈរស្ទូរក្បែរខ្លួនទើបប្រាប់ទៅថា៖

- ខ្ញុំមករកលោកហ្លួងរតនសម្បត្តិ វេលានេះលោកនៅឬទេ ?

បុរសនោះឆ្លើយតបថា៖

- លោកនៅខាងលើផ្ទះ បើចង់ជួបនឹងលោក អញ្ជើញមកតាមខ្ញុំ ហើយបុរសនោះក៏ដើរនាំមុខថៅចិត្រឡើងទៅលើផ្ទះ ។

គេប្រាប់ឲ្យថៅចិត្រអង្គុយលើកៅអីមួយ នៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយដើរចូលទៅក្នុងបាត់មួយស្របក់ ក៏លេចមនុស្សចាស់ សក់ស្កូវម្នាក់ដើរចេញមកដោយឫកពាអង់អាច ស្លៀកសារុងស្វូត្រពាក់អាវទ្រនាប់តាមទំនៀមអ្នកនៅផ្ទះ ពាក្យដំបូងដែលនិយាយនឹងថៅចិត្រនោះដូច្នេះថា ៖

- ក្មួយមកពីណា ? ត្រូវការជួបនឹងខ្ញុំមានការអ្វី ?

ថៅចិត្រសង្កេតដឹងច្បាស់ថា លោកនេះហើយដែលហៅថា ហ្លួងរតនសម្បត្តិដែលខ្លួនត្រូវការជួប ទើបរំកិលខ្លួនចុះពីកៅអីលុតជង្គង់ក្រាបចុះ ដោយសេចក្ដីគោរពគួរសម ។

ឯហ្លួងរតនសម្បត្តិជាអ្នកជំនួញលក់ត្បូង ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក្នុងស្រុកបប៉ៃលិន ក៏អង្គុយលើកៅអីមួយ ថៅចិត្រសង្កេតតាមឫកពារបស់លោកនេះ យល់ថាជាអ្នកមានអធ្យាស្រ័យល្អចិត្តសប្បុរស គួរជាទីគោរពរាប់អានបាន ។

- ទានប្រោសមាន...

ថៅចិត្រឆ្លើយដោយឱនលំទោនហើយថា៖

- លោកគ្រូពេទ្យស្អាតបានផ្ញើសំបុត្រមួយច្បាប់ មកជូនព្រះតេជ ព្រះគុណ។
- អើ ! ពេទ្យស្អាតក្មួយខ្ញុំនោះឬ ?

លោកនិយាយទាំងញញឹមតាមដោយលោកជាអ្នកមានអធ្យាស្រ័យរីករាយជានិច្ច ហើយសួរថា ៖

- សំបុត្រនោះនៅឯណា ?

ចៅចិត្រលូកដៃទៅក្នុងហោប៉ៅ យកសំបុត្រនោះជូនទៅ លោកហ្លួងទទួលយកទៅមើលដោយសេចក្តីត្រេកអរ លុះមើលចប់ហើយក៏បែរមកពិចារណា មើលលក្ខណៈចៅចិត្រម្តងទៀត ។

- ហ្លួង៖ ក្មួយឯងមែនទេ ឬអីឈ្មោះចៅចិត្រ ដែលពេទ្យស្អាតបានបញ្ជូនខ្លួនមកឲ្យខ្ញុំ ?
- ចៅចិត្រ៖ ទានប្រោស ខ្ញុំបាទនេះហើយ។
- ហ្លួង៖ ចុះក្មួយធ្វើការយ៉ាងនេះបានដែរឬ ? ការរបស់ខ្ញុំនេះវាធ្ងន់ណាស់ តោងទ្រាំជីកដីក្នុងមួយថ្ងៃ ប្រាំ ប្រាំមួយ ម៉ោងទើបស្មុះរួច រូបរាងស្អាតបាតដូចជាក្មួយនេះ ខ្ញុំយល់ថាទ្រាំទ្រការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ !
- មនុស្សដទៃទៀតគេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទគង់ធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឲ្យសោះ។

ចៅចិត្រពោលរ៉ាប់រង យ៉ាងម៉ឺងម៉ាត់ ពាក្យនេះហើយដែលធ្វើឲ្យហ្លួងរតនសម្បត្តិ មានសេចក្តីពេញចិត្តណាស់ ហើយចៅចិត្រនិយាយតទៅទៀតថា៖

- ទានប្រោស ! មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនត្រូវប្រកាន់ការស្រាលៗស្រួលៗទេ ខ្ញុំបាទមិនដែលគិតដូច្នេះទេ កាលបើខ្ញុំបាទមានកម្លាំងពលំដរាបណា ខ្ញុំបាទនឹងខំធ្វើការដរាបនោះ។
- ចៅចិត្រ អ្នកឯងនិយាយនេះត្រូវណាស់។

លោកហ្លួងនិយាយសរសើរ ហើយថា៖

- ល្មើយចុះ ឯខ្ញុំតែងមានការសម្រាប់មនុស្សដែលចង់ធ្វើជានិច្ច វេលានេះ អណ្តូងត្បូងទិសខាងកើត ខ្ញុំកំពុងឲ្យចាប់ផ្តើមជីកត្បូងមានតម្លៃមួយអន្លើ ព្រឹកស្អែកនេះខ្ញុំនឹងបញ្ជូនអ្នកឯងឲ្យទៅធ្វើការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះ ខ្ញុំនឹងតាំងប្រាក់ខែឲ្យអ្នកឯង

ត្រឹម៣០ រៀលសិន ប៉ុន្តែអ្នកឯងអាចបានប្រាក់ខែច្រើនជាងនេះទៅទៀត បើខំយកចិត្តទុកដាក់ធ្វើការយ៉ាងម៉ឺងម៉ាត់ ។

ថៅចិត្រឱនក្បាលក្រាបចុះដោយសេចក្ដីគោរពម្ដងទៀត ហើយពោលថា៖

- សូមអរគុណព្រះតេជ ព្រះគុណជាទីបំផុត ព្រះតេជ ព្រះគុណកំពុងធ្វើខ្ញុំបាទឲ្យបានជាមនុស្សម្នានឹងគេឡើង ខ្ញុំបាទពេញចិត្តនឹងការដែលព្រះតេជព្រះគុណ ប្រគល់ឲ្យធ្វើនោះជាទីបំផុត។

ក្នុងខណៈនោះ មានសូរស្បែកជើងលាន់ឮពីខាងក្រោមឡើងមកលើផ្ទះ ព្រមទាំងមានសំឡេងយ៉ាងឆ្មារតូចលាន់រំពងមកពីខាងក្រោយ ថៅចិត្រក៏ចោលភ្នែកក្រឡេកមើលទៅ ប្រទះនឹងភ្នែកទាំងគូកំពុងតែសំឡឹងចំត្រង់មក ជាដួងភ្នែកប្រកបដោយទឹកដម គួរជាទីចាប់ចិត្តស្នេហា តែមានឫកពាឆ្មើងឆ្មៃបន្តិច កិរិយាក្និកក្នក់ញ៉ែងញ៉ង ល្វាសល្វន់ ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង្សព្រះចន្ទ្រ សូរសំឡេងស្រស់ដូចសូរគាំងប្រាក់ ដំណើរល្វន់ល្វាសដូចផ្កាកូលាបដែលត្រូវខ្យល់បក់ល្វិចៗ នៅកណ្ដាលសួនច្បារដូច្នោះ ឱ ! ល្អអីម្ល៉េះ ! នេះប្រហែលជាអញយល់សប្ដិឃើញទេដឹង !!

ថៅចិត្រភ្ញាក់ស្មារតីលែងសំឡឹងស្រឡាំងកាំង ក្នុងពេលដែលលោកហ្លួងស្រែកហៅកូនក្រមុំនោះឲ្យឡើងមកខាងលើផ្ទះ៖

- មកឯណេះ នារីថ្ងៃនេះ ប៉ាបានមនុស្សចូលធ្វើការថ្មីម្នាក់ទៀ។

នាងក្រមុំនារី ឈានជើងឡើងជណ្ដើរមួយៗ ភ្នែកសំឡឹងមើលថៅចិត្រដោយកិរិយាឆ្មើងឆ្មៃបន្តិច ដែលជាទំនៀមរបស់ស្រីក្រមុំរូបស្រស់ ហើយសួរទៅឪពុកថា៖

- ប៉ា ! នេះឬអ្នកចូលមកធ្វើការថ្មីរបស់យើង ?

លោកហ្លួងញាក់មុខទទួលហើយ ងាកទៅនិយាយនឹងថៅចិត្រថា៖

- ថៅចិត្រ ! នេះនារីកូនក្រមុំរបស់ខ្ញុំ។

ថៅចិត្រលើកដៃសំពះសួរ នាងនារីងក់ក្បាលគំនាប់ដោយកិរិយាឆ្មើងៗ តាមនិស្ស័យរបស់នាង ។ ថៅចិត្រដឹងខ្លួនថា តាំងអំពីថ្ងៃនេះទៅ មុខជាត្រូវនាងក្រមុំរូបស្រស់នេះមាក់ងាយ មាក់ថោក ខ្លះជាមិនខាន ។

នាងនារី សំឡឹងមើលកម្មករថ្មីរបស់ឪពុក តាំងអំពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ថា *កម្មករនេះស្គមដូចជាអ្នកញៀនអាភៀន នឹងមានកម្លាំងជីកដីបានឬប៉ា ? កូនយល់ថាតម្រូវឲ្យធ្វើការលាងចានក្នុងផ្ទះបាយវិញជាជាង ?

ថៅចិត្រកាលត្រូវស្រីក្រមុំស្តីដាក់មុខដូច្នេះ ក៏នឹកអៀនខ្មាសណាស់ ក្រឡេកចោលកន្ទុយភ្នែកទៅនាងមួយភ្លែតហើយតបទៅថា៖

- មនុស្សត្រង់គេមិនដែលសំគាល់ថាជាមនុស្សល្ងង់ ឯមនុស្សស្គមក៏គេមិនសំគាល់ថាជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទនេះ មានកម្លាំងខ្លាំងដូចជាមនុស្សធាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមបរិបូណ៌ទេតើ !!

នាងនារីធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកនាថាថៅចិត្រហ៊ានឆ្លើយដូច្នោះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះ ហ៊ាននិយាយលេងសំដីរោហារនឹងនាងឡើយ ។

លោកហ្លួងឃើញកូនខឹងដូច្នោះ ក៏និយាយបញ្ឈប់ថា៖

- ថៅចិត្រ ! ឈ្ងើយឈប់ស្លេះប៉ុណ្ណឹងសិនចុះ ឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសម្រាកខ្លួនឲ្យបាត់នឿយហត់សិនទៅ៕

# រឿងកុលាបប៉ៃលិនវគ្គទី៣

តាំងពីថ្ងៃនោះមក ចៅចិត្រក៏បានធ្វើជាកម្មករជីកត្បូងនៅគេហស្ថាន របស់ហ្លួងរតនសម្បត្តិ ទោះបីការនោះជាការធ្ងន់ក៏ដោយ ចៅចិត្រក៏ឥតមានចិត្តធុញទ្រាន់ តែងតែខំធ្វើការនោះដោយខ្មីឃ្មាតអស់ពីចិត្តពីថ្លើម មិនមាននឹកនាដល់សេចក្ដីនឿយហត់ឡើយ ។ ភាសិតមួយ បទថា **ខ្លួនជាទីពឹងរបស់ខ្លួន** ដែលជាពាក្យបណ្ដាំរបស់បិតានោះ នៅឮសូរកងរំពងក្នុងត្រចៀករបស់ចៅចិត្រ ហាក់ដូចជាមានទេវតាមកចាំខ្សឹបប្រាប់នឹងត្រចៀកជានិច្ច ។ ការខំប្រឹងធ្វើការយ៉ាងម៉ឺងម៉ាត់ឥតមានទម្រន់នឹងអធ្យាស្រ័យល្អ របស់ចៅចិត្រនោះ ជាហេតុធ្វើឲ្យពួកអ្នកធ្វើការជងគ្នាស្រឡាញ់រាប់អានជាច្រើន រហូតដល់ហ្លួងរតនសម្បត្តិ ក៏មានចិត្តមេត្តាក្មេងកម្លោះនោះជាច្រើនដែរ ។

ចៅចិត្រចូលមកធ្វើការនៅផ្ទះលោកហ្លួងរតនសម្បត្តិ អស់វេលា២ខែកន្លងមកហើយនោះ តែងបានជួបប្រទះនឹងធម្មជាតិថ្មីៗ ដូចជាព្រៃភ្នំក្រំថ្ម ព្រឹក្សាលតាវល្លិ និងអាកាសស្រស់បរិសុទ្ធ ដែលជារបស់ចំឡែកក្នុងជីវិតចៅចិត្រ តែដែលចំឡែកយ៉ាងពន្លឹកជាងនេះទៅទៀតនោះ គឺនាងនារីចៅហ្វាយក្រមុំរបស់ចៅចិត្រ ដែលជាស្ត្រីប្រកាន់ខ្លួនមានឫកពាឆ្មើងឆ្មៃ ហើយជានារីមានរូបឆោមយ៉ាងល្អឯកក្នុងស្រុកបប៉ៃលិន ហាក់ដូចជាផ្កាកុលាបកំពុងរីក ផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ក្នុងវស្សានរដូវ ។ វេលាដែលចៅចិត្រអង្គុយក្នុងផ្ទះស្ងាត់ៗតែម្នាក់ឯង ច្រើនប្រមូលយករឿងអស់នេះមកគិតនឹកជានិច្ច ហើយនឹកឆ្ងល់តែម្នាក់ឯងថា**ចុះហេតុដូចម្ដេចបានជាអញចេះតែរំពឹងនឹកដល់នាងក្រមុំនេះអី ម្ល៉េះ ចុះអញជាប់ចិត្តប្រតិព័ទ្ធនាងក្រមុំនេះឬអ្វី ? អា ! មិនបានទេ នាងនេះរូបឆោមល្អមែនហើយ ប៉ុន្តែឫកពាឆ្មើងឆ្មៃប្រកាន់ខ្លួនហួសពេក ថែមទាំងយសស័ក្តិក៏ខ្ពង់ខ្ពស់ណាស់ ហួសវិស័យនឹងឈោងតោងបេះប្រលេះយកឲ្យបាន ចុះមានប្រយោជន៍អ្វីដែលអញនៅខំគិតនឹកដល់គេ ទុកជាខំទប់ចិត្តមិនឲ្យនឹកគិតដូចម្ដេចៗ ក៏នៅតែមានចិត្តរិះរេទៅរករូបារម្មណ៍នោះទាល់តែបាន** !!!

ចំណែកខាងនារីក៏ធ្លាប់គិតថា កម្មករថ្មីរបស់នាងនេះ ជាមនុស្សចំឡែកជាងគេ មិនចេះប្រចុបប្រចែងចៅហ្វាយនាយ និយាយដូចជាគេចោលដឹងទាំងដង ឥតចេះក្រែងចិត្តគេសោះ ថែមទាំងចេះនិយាយសំដីទាន់សម័យទៀតផង បានជានាងមិននឹកជឿថា កម្មករកម្លោះនោះបានរៀនសូត្រត្រឹមសាលាជាន់ទាប គ្រាន់តែចេះសរសេរ ចេះមើលប៉ុណ្ណោះទេ ។ ចួនកាលនាងបានឮបុរសកម្លោះនោះ ស្រែកច្រៀងរាយទំនុកតាមការកំសត់របស់ខ្លួនក៏មាន ច្រៀងទំនុកយុវាភិរម្យជាពាក្យរំឮកយុវជនក៏មាន ទើបនាងយល់ថា កម្មករកម្លោះនោះ ច្បាស់ជាចេញមកពីសាលា

បបមសិក្សាជាន់ខ្ពស់ជាប្រាកដ ។ នៅវេលាព្រលប់ថ្ងៃនោះជាខាងរនោច ព្រះចន្ទ្រក៏រះឡើងបំព្រាងៗ មើលឃើញផែបមួយចំហៀង ឆ្លុះពន្លឺពណ៌ប្រផេះគងលើចុងព្រឹក្សាយ៉ាងត្រចះត្រចង់ នារីចុះមកដើរលេងកំសាន្តចិត្តជាមួយនឹងស្រីបំរើម្នាក់ នៅទីធ្លាសួនច្បារមុខផ្ទះដែលមានស្មៅរាបស្អាតដូចកម្រាលព្រំ នាងតែងតែចោលភ្នែកក្រឡេកមើលទៅកូនផ្ទះមួយ ដែលថៅចិត្រនៅជាញយៗ ។ ពេលនោះនាងបានឃើញផ្ទះនោះងងឹតឥតពន្លឺភ្លើង ទើបនាងនាំក្មេងស្រីបំរើ ហើយលបដើរឆៀងចូលទៅឈរនៅគុម្ពផ្កាដកខិមខាងមុខបង្អួច ក៏ស្រាប់តែឮសូរសំឡេងមនុស្សច្រៀង ទំនុកយុវាភិរម្យយ៉ាងពិរោះចាប់ចិត្តថា៖

| | |
|---|---|
| ពួកយើងជាគណយុវជន | ស្រុះស្រួលលើសលន់ទាំងប្រុសទាំងស្រី |
| ចូរយុវសាលាដែលទើបកើតថ្មី | ប្រយោជន៍ដើម្បីជួយជ្រោមជ្រែងគ្នា ។ |
| ឲ្យបានចងបាច់ជាក្រុមមិត្រភ័ក្ត្រ | ស្រឡាញ់រួមរ័ក្សជាសមគ្គា |
| សាមគ្គីទាំងជាតិយើងផងនានា | មេត្រីគ្រប់គ្នាជាសុខក្សេមក្សាន្ត ។ |
| គួរជួយអ្នកខ្សត់ឲ្យបានចេញទៅ | ដើរមើលលំនៅសព្វទីភូមិឋាន |
| មើលស្រែចំការនឹងច្បារឧទ្យាន | កិច្ចការប៉ុន្មានតោងចងចាំទុក១ ។ល។......... |

នាងនារីឈរស្តាប់ទំនុកនោះហើយ ទើបនាងដើរឡើងស្លៅទៅលើផ្ទះនោះយ៉ាងរួសរាន់ ដើម្បីចាប់អ្នកច្រៀងនោះឲ្យស្គាល់មុខច្បាស់ តើគឺនរណា ? តែនាងមិនបានឃើញមនុស្សអង្គុយច្រៀងនៅទីនោះទេ បែរជាឃើញថៅចិត្រដេកលក់សណ្តូកជើងត្រង់ស្តូក ស្រមុខគយរ នៅលើគ្រែក្បែរមាត់បង្អួច ក្រឡេកមើលឆ្វេងមើលស្តាំ ក៏ឥតឃើញនរណាម្នាក់សោះ ក្រៅពីរូបថៅចិត្រកំពុងដេកលក់ស្រមុខគខេរតែម្នាក់ឯង នាងនឹកឆ្ងល់ណាស់ ព្រោះអម្បាញ់មិញនេះឮសូរស្រែកច្រៀងក្តែងៗ ចុះអ្នកឯណាមកលបស្រែកច្រៀងនៅទីនេះអេះ ?

វេលានោះ រស្មីព្រះចន្ទ្រកំពុងតែចាំងចូលមកតាមចន្លោះបង្អួច នឹងចន្លោះទ្វារ ទើបនាងមើលទៅឃើញរាងកាយថៅចិត្រដេកលក់ស្តូកស្តឹង នៅទីនោះយ៉ាងច្បាស់លាស់ នាងក៏ស្រែកដាស់ថៅ

ចិត្រ ពីរ បី ម៉ាត់ ចៅចិត្រក៏ប្រែខ្លួនស្ទុះក្រោកឡើងទាំងងងុយងោក កាលឃើញអ្នកដែលចូលមកដាស់ច្បាស់ហើយ ក៏មីម្នានិយាយអញ្ជើញឲ្យអង្គុយដោយកិរិយាឱនលំទោន ។

- អញ្ជើញអង្គុយ យុននារី ១។

ចៅចិត្រនិយាយព្រមទាំងលើកកៅអីមួយជូននាងអង្គុយ ហើយនិយាយថា៖

- ការដែលយុនអញ្ជើកលេងផ្ទះខ្ញុំបាទនេះ ខ្ញុំបាទមានសេចក្តីត្រេកអរណាស់ទុកដូចបានទទួលកិត្តិយសដ៏ ខ្ពង់ខ្ពស់ !

នាងនារីធ្វើមុខក្រញូវបន្តិចហើយស្តីទៅថា៖

- អ្នកណានិយាយថា ខ្ញុំមកលេងនឹងអ្នកឯង !

ចៅចិត្រនឹកសង្ស័យក៏សួរទៅវិញថា៖

- ចុះយុនអញ្ជើញមកមានការអ្វី ?

នាងតបទៅវិញយ៉ាងកំបុតកំបុយថា៖

- ខ្ញុំមកស្តាប់មនុស្សច្រៀងទេតើ ចុះអម្បាញ់មិញនេះអ្នកណាច្រៀងទំនុកយុវាភិរម្យក្តែងៗក្នុងទីនេះ ?

ចៅចិត្រធ្វើភ្នែកឡឹងឡង់ និយាយសួរទៅនាងថា៖

- ទានប្រោស យុវាភិរម្យជាអ្វី ជាសត្វឬជាមនុស្ស ខ្ញុំបាទមិនដែលឮឈ្មោះសោះឡើយ ?

នាងនារីខឹងឡើងមុខក្រហម ហើយប្រាប់ទៅថា៖

- នែ ! អ្នកភ្លើ យុវាភិរម្យជាទំនុកភ្លេងមួយ ខ្ញុំចង់ដឹងតើអម្បាញ់មិញនេះនរណាច្រៀង ?
- ចិត្រ៖ អេ ទេ នរណាច្រៀងខ្ញុំបាទឥតដឹងសោះឡើយ តែខ្ញុំបាទមិនមែនច្រៀងទេ ឯខ្ញុំបាទនេះកុំថាដល់ទៅភ្លេងយុវាភិរម្យ ជាទំនុកទំនើបថ្មីអ្វីនោះឡើយ តែបទសកវាទិចុះផៃអុំទូករាល់ឆ្នាំនោះ ខ្ញុំបាទក៏ឥតចេះនឹងគេសោះឡើយ។

- នារីៈ កុំភូត ខ្ញុំបានឮស្ករសំឡេងច្រៀង អំពីខាងលើផ្ទះនេះឯង ហើយនៅលើផ្ទះនេះ ក៏មានតែអ្នកឯងម្នាក់ឯងមែនទេ ?
- ចិត្រៈ បាទ មានតែខ្ញុំបាទម្នាក់ឯងមែន តែខ្ញុំបាទមិនមែនជាអ្នកច្រៀងទេ !
- អ្នកឯងច្រៀងក្តែងៗនៅតែប្រកែកនឹងគេទៀត។

នារីផ្ទួនពាក្យ ។

ចៅចិត្រសើចហើយថាៈ

- ខ្ញុំបាទជំរាបហើយថា ខ្ញុំបាទមិនចេះច្រៀងទេ ក៏នៅតែបង្ខំឲ្យច្រៀងទៀត យុននារី បើខ្ញុំបាទចេះច្រៀង នឹងច្រៀងជូនយុនស្តាប់ឥឡូវនេះឯង។

នាងនារីនឹកខឹងរលាស់មុខស្មុះក្រោកឡើងឈរហើយថាៈ

- មនុស្សបែបនេះនិយាយខ្មែរមិនចេះស្តាប់ទេ។
- ចិត្រៈ បើមិនចេះស្តាប់ភាសាខ្មែរ ហេតុអ្វីក៏និយាយឆ្លើយឆ្លងគ្នាបាន ?
- នារីៈឈប់ៗចិត្រ កុំនិយាយថ្លង់ណាស់។

នាងលើកដៃហាម ហើយនាងប្រុងនឹងចុះពីផ្ទះនោះទៅដោយរួសរាន់ តែចៅចិត្រអង្វរឃាត់ថាៈ

- ពុទ្ធោ ! យុននារី យុនប្រញាប់អញ្ជើញទៅណាភ្លាម ?

នាងឆ្លើយយ៉ាងសោះកក្រោះថា

- ទៅដេក។
- ចិត្រៈ យុន កុំអាលអញ្ជើញទៅ យុនមិនគួរលះបង់ធម្មជាតិល្អៗ ដ៏ត្រកាលដែលគួរពិតពិលរមិលមើលក្នុងវេលានេះទៅទេ ។
- នារីៈ ខ្ញុំក៏ចូលចិត្តធម្មជាតិល្អៗដូច្នេះដែរ តែស្អប់មនុស្សឆ្កួតព្រើលៗ។
- នៅទីនេះឥតមានមនុស្សឆ្កួតទេ យុន។

ចៅចិត្រខ្ជិលនិយាយជជែកតទៅទៀត បែរជានិយាយបបួលដោយស្រួលថាៈ

- ណ្ហើយយុន មិនបាច់និយាយជជែកគ្នាច្រើនទេ សូមអញ្ជើញចុះទៅសន្ទនាលេងក្នុងសួនច្បារឯណោះ មើលធម្មជាតិល្អៗ ដ៏ត្រកាលកម្រមានណាស់ !

មិនដឹងជាអំណាចអ្វី មកគ្របសង្កត់នាំឲ្យនាងនារីធ្វើតាមចិត្តរបស់ថៅចិត្រ ស្រាប់តែចុះដើរនាំមុខទៅដោយស្រួល ទៅអង្គុយលើជើងម៉ាវែងក្បែរដើមចំប៉ីមួយដើម ។ ឯថៅចិត្រក៏អង្គុយលើស្មៅក្បែរជើងម៉ានុះដែរ តែភ្នែករំពៃងើយមើលទៅព្រះចន្ទ្រផែបពាក់កណ្ដាល ដ៏ដេរដាសទៅដោយពពួកផ្កាយ មានចំនួនច្រើនលើសលន់គណនា ហើយថៅចិត្រនិយាយឡើងថា៖

- យុនគាប់ចិត្តពន្លឺរស្មីដួងព្រះចន្ទ្រឬទេ ?
- នារី៖ ខ្ញុំចូលចិត្តដែរ ចិត្រ ។

ថៅចិត្រនិយាយដោយសំដីទន់ផ្អែមថា៖

- មែនហើយ ! យុននារី ! ធម្មជាតិជារបស់ចំឡែកនេះ អាចប្រលោមលួងលោមអារម្មណ៍របស់មនុស្សយើងឲ្យបានសុខស្រួល ពន្លឺរស្មីព្រះចន្ទ្រ ខ្យល់រំភើយផាត់ និងក្លិនក្រអូបឈ្ងុយឈ្ងប់របស់ផ្កានានា អាចធ្វើចិត្តគំនិតរបស់យើងឲ្យមានអារម្មណ៍រីករាយទៅបានយ៉ាងចំឡែក ។

នាងអង្គុយស្ដាប់សំដីថៅចិត្រនិយាយដោយអារម្មណ៍អណ្ដែតអណ្ដូង ក៏គិតថា៖

- កម្មកកម្លោះនេះ ជាមនុស្សចំឡែកជាងកម្មករឯទៀតៗរបស់នាង សំដីគ្រប់ៗម៉ាត់របស់កម្មករនេះ ពេញទៅដោយសំនួនវោហារមុខគួរឲ្យចង់ស្ដាប់ មិនសមជាមនុស្សខ្សោយចំណេះចេះដឹងទេ ។

នាងនារីស្ងាត់មាត់ទៅមួយស្របក់ ថៅចិត្រក៏ផ្ដើមនិយាយឡើងមុនថា៖

- បើយុនតែម្នាក់ឯងអង្គុយជាមួយនឹងធម្មជាតិបែបនេះ តើយុនធ្លាប់នឹកប្រវត្តិដល់ញាតិមិត្រសំឡាញ់ ដែលនៅឆ្ងាយខ្លះដែរឬ ?
- នាង៖ ខ្ញុំធ្លាប់នឹកដែរ ចិត្រ។
- ចិត្រ៖ ខ្ញុំបាទក៏ធ្លាប់នឹកដែរ ហើយច្រើនតែជាប់នៅនឹងចិត្តជានិច្ចផង ឱ ! យុននារីតាំងអំពីខ្ញុំបាទមកនៅអាស្រ័យនឹងផ្ទះយុននេះ ខ្ញុំបាទមិនដែលឃើញអ្នកម្ដាយរបស់យុនដល់ម្ដងសោះ។

- ចិត្រ៖ អេះ ! ចំឡែកដែរ បើយុនគ្មានម្ដាយ យុនកើតមកដូចម្ដេចបាន ?
- នារី៖ យីអើ ! នែ គាត់ឯងកុំនាំអុចអាលបណ្ដាលឲ្យកើតទោសោណា ពាក្យដែលថាគ្មានម្ដាយនោះ គឺថាម្ដាយនោះគាត់អនិច្ចកម្មទៅ ហើយយល់ទេ ?
- ចិត្រ៖ ឱ ដូច្នោះទេឬ ? យល់ហើយទានប្រោស តែយុននៅគ្រាន់បើជាងខ្ញុំបាទច្រើន !
- នារី៖ អើ ! ម្ដាយគាត់ឯង គាត់ខូចបង់ទៅហើយដែរឬ ?

ថៅចិត្រធ្វើមុខស្រពោនហើយថា៖

- យុននៅគ្រាន់បើជាងខ្ញុំបាទច្រើន ព្រោះមានឪពុកបីបាច់រក្សា ចំណែកខាងខ្ញុំបាទ គ្មានទាំងឪពុកទាំងម្ដាយ។

ត្រង់នេះ នាងនារីសង្កេតមើលទឹកមុខថៅចិត្រ ឃើញស្ងួតស្រពោនទៅច្រើន ថៅចិត្រសន្សឹមៗងើយមុខមើលទៅមុខនាង ហើយនិយាយថា៖

- ប្រសិនបើធៀបខ្លួនយុនជាខ្ញុំបាទវិញ ហើយថែមទាំងជាស្ត្រីផង យុនតោងគិតថា ការតស៊ូនឹងជីវិតដែលក្រីក្រលំបាកតោកយ៉ាកទៅតាមទំនើងតែម្នាក់ឯង នុះ តើវាមានរសជាតិដូចម្ដេចខ្លះ ? តែខ្ញុំបាទជាប្រុសល្មមអត់ធ្មត់សេចក្ដីលំបាកបានគ្រប់ៗយ៉ាង ហើយធ្លាប់តទល់នឹងសេចក្ដីក្រីក្រតោកយ៉ាកមកច្រើនហើយ ចួនកាលខ្ញុំបាទអត់បាយពេញ១ថ្ងៃក៏មាន។

នាងនារីអង្គុយសំងំស្ងៀមចាំស្ដាប់ថៅចិត្រនិយាយ តែក្នុងចិត្តនឹកអាណិតអាសូរថៅចិត្រជាពន្លឹកហើយនឹកដល់ខ្លួនឯង ថា បើអញត្រូវបានទទួលគ្រោះថ្នាក់យ៉ាងនេះផង តើនឹងមានសេចក្ដីលំបាកយ៉ាងណាទៅ !

- នារី៖ ចុះចិត្រមកនៅទីនេះ បានស្រួលខ្លះហើយឬនៅឡើយទេ ?

នាងនិយាយតិចៗហើយមានសំឡេងទន់ជាងមុនច្រើន ។

ថៅចិត្រសំឡឹងមើលភ្នែកនាងនារី ហើយញញឹមយ៉ាងរោះរាយឆ្លើយថា៖

- ខ្ញុំបាទបានស្រួលច្រើន ! យុននារី តាំងអំពីខ្ញុំបាទចូលមកអាស្រ័យនៅក្នុងផ្ទះយុននេះស្រួលចិត្តឡើងច្រើន មិនបាច់នឹកព្រួយក្រែងអត់បាយស្លាប់ បើបប៉ៃលិននៅតែមានមេត្តាខ្ញុំបាទយ៉ាងនេះជានិច្ចទៅ ខ្ញុំបាទមុខជាសូមធ្វើឆ្អឹងនៅជំបន់នេះជាប្រាកដ !

អាកាសនៅប៉ៃលិន តាមធម្មតាត្រជាក់ជាងស្រុកសង្កែបាត់ដំបងច្រើន បើចួនជាត្រូវរដូវរងា ដូចក្នុងវេលានោះ ក៏កាន់តែត្រជាក់ខ្លាំងឡើងទៀតជាច្រើន លុះឮសូរទឹកសន្សើមស្រក់ចុះពីស្លឹកឈើមិនដាច់រយៈ ដួងចន្ទ្រមួយចំហៀងនោះក៏លិចបាត់បាំងដងភ្នំទៅ ខ្យល់ត្រជាក់ក៏កាន់តែបក់ផាត់ខ្លាំងឡើង ជាហេតុនាំឲ្យត្រជាក់ញាក់ដល់បេះដូងកម្លោះក្រមុំទាំងពីរនាក់។ ទើបថៅចិត្រសន្សឹមក្រោកឡើងមើលទៅផ្ទៃមេឃដោយកិរិយាស្រពោនស្រពន់ ហើយនិយាយឡើងថា៖

- យប់ជ្រៅហើយ យុននារី អញ្ជើញឡើងទៅផ្ទះវិញចុះ អំណាចទឹកសន្សើមនិងខ្យល់រងាបែបនេះ អាចធ្វើឲ្យយុនផ្ដាសាយ ឬទៅជាគ្រុនក៏សឹងបាន !

ឯនាងនារីក្រោកដើរឡើងទៅលើផ្ទះដោយស្រួល ដូចកូនក្មេងដែលប្រដៅបានបែបបទល្អ តែនាងមកនឹកឆ្ងល់ក្នុងចិត្តថា៖

- កម្មករកម្លោះនេះ មានអំណាចអ្វីហ្ន៎ ! អាចហ៊ានបង្គាប់អញឲ្យធ្វើតាមបង្គាប់ខ្លួនបានដោយងាយដូច្នេះ។

តែនាងក៏គិតយល់ថា៖

- ប្រសិនបើអញនៅហាលសន្សើមយូរពេកអាចធ្វើឲ្យគ្រុនរងា ឬផ្ដាសាយបានមែន ។

លុះដល់ព្រឹកឡើង ថៅចិត្រក៏លីចបដើរចេញទៅធ្វើការជីកត្បូងនាអណ្ដូងត្បូង ត្រង់ទិសខាងកើតដូចសព្វដង ដែលធ្លាប់ធ្វើមករាល់ៗថ្ងៃ បានដើរកាត់មុខផ្ទះធំនោះទៅ ស្រាប់តែឃើញនាងនារី និងលោក ហ្លួងរតនសម្បត្តិ អង្គុយក្នុងរថយន្ត យីហោ រ៉ឺណូត៍ ដែលជារថយន្តសម្រាប់ប្រើទៅទិញអីវ៉ាន់នៅផ្សារសង្កែ ។ ឯតាសុន ជាអ្នកបររថនោះ ខំប្រឹងវៃទាល់តែបែកញើស ក៏នៅតែមិនឆេះសោះ ដល់យូរពេកណាស់ទើបលោក ហ្លួងស្រែកសួរទៅថា៖

- តាសុន រថយន្តមិនឆេះទេឬ ?

តាសុនគ្រវីក្បាល យកកន្សែងជូតញើសមុខ ហើយជំរាបទៅលោកហ្លួងថា៖

- មិនឆេះទេ ទានប្រោស ! ខ្ញុំបាទបានដោះលាងសំអាតគ្រឿងអំពីយប់មិញនេះឯង ស្រាប់តែព្រឹកឡើងវាគៀចដូច្នេះទៅ !

ថៅចិត្រដើរចូលមកជិត លើកដៃសំពះលោកហ្លួង ហើយជំរាបសួរថា៖

- ទានប្រោស ព្រះតេជព្រះគុណអញ្ជើញទៅឯណា ?

លោក ហ្លួងតបទៅថា៖

- ខ្ញុំទៅទទួលលោក បាឡាត់ស្រុក ឯស្រុកសង្កែបន្តិច តែរថវាមិនព្រមឲ្យទៅសោះ ថៅចិត្រ !

នាងនារីសំឡឹងមើលថៅចិត្រមួយភ្លែត ឃើញទឹកមុខដូចជាស្រស់បស់ជាងសព្វថ្ងៃ មានកិរិយាអង់អាចខុសពីកម្មកររងទៀតៗ ។

- នារី៖ ប៉ា ! យើងទៅមិនរួចទេឬអ្វី ?

នាងសួរដោយសេចក្ដីព្រួយ ។

- ចិត្រ៖ សុំឲ្យខ្ញុំបាទរវៃមើលបន្តិច ក្រែងលោឆេះឡើងបាន។

ហើយថៅចិត្របើកគ្របបាំងគ្រឿងយន្តពិនិត្យមើលមួយស្របក់ក៏ញញឹម ហើយនិយាយថា៖

- ទានប្រោស ទាស់ត្រង់ណេះ រវៃម្ដងទៀតឆេះជាប្រាកដ ហើយប្រាប់តាសុនឲ្យរវៃម្ដងទៀត ។

តាសុនចាប់រវៃម្ដងទៀត គ្រឿងយន្តក៏គ្រហឹមគឹកកង មួយរំពេចឡើង អ្នកទាំងអស់គ្នាក៏ញញឹម តាសុនក៏ទៅទះស្មាថៅចិត្រហើយ លាន់មាត់ថា៖

- ពូកែគ្រាន់បើ អ្នកក្មួយអញ !

លោកហ្លួង ក៏លាន់មាត់ដោយសេចក្ដីត្រេកអរ ហើយសួរថៅចិត្រថា៖

- ថៅចិត្រពូកែមែន រៀនចេះពីណា ប្រសប់លាក់ចំណេះណាស់ ?

ថៅចិត្រនឹកត្រេកអរ បង្អោនខ្លួនជំរាបទៅលោកហ្លួងថា៖

- ទានប្រោស មិនបានរៀនឯណាទេ គ្រាន់តែធ្លាប់បររថយន្តមកដែរ ក៏ល្មមធ្វើកើតចំពោះតែគ្រឿង ដែលខូចខាតបន្តិចបន្តួចប៉ុណ្ណោះ។

ហើយចាប់ចបលើកលីលើស្មា ។

ឯតាសុន បានឮសំដីថៅចិត្រថា **ធ្លាប់បររថយន្តមកដែរ** ក៏នឹកដល់ប្រពន្ធដែលទើបមកដល់ផ្ទះពីព្រឹកមិញនេះ គាត់មិនទាន់បានសាកសួរអំពីសុខទុក្ខសោះ ស្រាប់តែជាប់រវល់មកបររថយន្តជូនលោកហ្លួងទៅស្រុកសង្កែ ទើបគាត់ជំរាបសុំច្បាប់លោកហ្លួងថា៖

- ទានប្រោស ថ្ងៃនេះខ្ញុំបាទមានធុរៈ ដ្បិតប្រពន្ធខ្ញុំបាទទើបមកដល់ផ្ទះព្រឹកមិញនេះ ខ្ញុំបាទមិនទាន់បានសាកសួរសុខទុក្ខ វាថាប្រញាប់វិលទៅស្រុកវិញ ក្នុងវេលាថ្ងៃត្រង់នេះផង ដូច្នេះសូមព្រះតេជព្រះគុណមេត្តាឲ្យថៅចិត្របររថយន្តជំនួសខ្ញុំ បាទមួយពេលសិនចុះ។

ហ្លួងរតនៈសម្បត្តិស្មៀមមួយស្របក់ហើយ បែរទៅសួរថៅចិត្រថា៖

- ចិត្រ ឯងបររថយន្តជំនួសតាសុនមួយថ្ងៃបានទេ ?

ថៅចិត្របែរទៅមើលតាសុន ឃើញសំដែងអាការអង្វរ ទើបថៅចិត្រជំរាបទៅលោកហ្លួងថា៖

- ខ្ញុំបាទបរជូនបាន ទានប្រោស។

តាសុនត្រេកអរណាស់ ស្ទុះទៅចាប់ដៃថៅចិត្រអង្រួនថា៖

- អរគុណអ្នកក្មួយណាស់ សូមអ្នកក្មួយសំឡាញ់ជួយយកតែបុណ្យទៅចុះ ហើយគាត់ងាកមកលើកដៃសំពះលាហ្លួងរតន សម្បត្តិដើរចេញទៅ។

ថៅចិត្រយកគ្រឿងប្រដាប់ធ្វើការទៅទុកស្រេចហើយ ក៏ផ្លាស់សំពត់អាវកម្មករជាអ្នកបររថយន្តឡើងកាន់ចង្កូតបរចេញពីទីនោះទៅ ទំនងជាអ្នកឆ្លាតប៉ិនប្រសប់ដោយមិនមានឧបសគ្គ រវាងពាក់កណ្តាលផ្លូវដរាបដល់ស្រុកសង្កែ ដែលជាទីក្រុងបាត់ដំបង ។ ឪពុកនឹងកូន ក៏ចុះពីរថយន្តដើរសំដៅទៅកាន់ផ្ទះមួយក្បែរសាលាស្រុក ប្រហែលជាកន្លះម៉ោងទើបឃើញនាងនារីចុះពីផ្ទះនោះមក ។

ថៅចិត្រសួរដោយកិរិយា សុភាពថា៖

- ត្រឡប់ទៅឥឡូវឬនៅទេ យុន ?
- នៅទេ នាងតបកំបុតៗហើយថា ចិត្រតោងទៅទិញអីវ៉ាន់ឯផ្សារជាមួយនឹងខ្ញុំឥឡូវ នុះក ញ្ជ្រែង ចិត្រកាន់យកទៅផងណា។

ថៅចិត្រនឹកភាំងបន្តិច ដ្បិតតាំងអំពីកើតមកមិនដែលកាន់កញ្ជ្រែងដើរតាមក្រោយស្រីណាម្ដង សោះ តែគ្រានេះត្រូវតែធ្វើតាម ដ្បិតគេជាថៅហ្វាយខ្លួន ឲ្យប្រាក់ខែខ្លួន ទុកជាការធ្វើដូច្នេះនាំឲ្យ អាម៉ាស់មុខយ៉ាងណា ក៏ត្រូវតែប្រតិបត្តិតាមបង្គាប់ទៅសិនចុះ ទើបនាយចិត្តស៊ូកាត់កេរ្តិ៍ខ្មាស ចាប់កញ្ជ្រែងដើររ៉ុយតាមក្រោយ ថៅហ្វាយក្រមុំ មានរូបឆោមស្រស់ប្រិមប្រិយនោះទៅ ។

- នារីបង្គាប់៖ ចិត្រ ទៅសួរទិញត្រីរ៉ស់ធំៗ ពីរយកទៅស្ងោរជ្រក់ តើគេលក់មួយថ្លៃប៉ុន្មាន ? រើសឲ្យធាត់ៗបន្តិច ។
- ថៅចិត្រនិយាយសុំខ្លួនថា៖ សូមកុំប្រើឲ្យខ្ញុំបាទទិញឡើយ យុន ! ហើយនិយាយតទៅ ទៀតថា៖ តាំងពីខ្ញុំបាទកើតមក ខ្ញុំបាទមិនដែលទិញត្រីសាច់ ឬ បន្លែបង្ការអ្វីទេ ក្រែង យុនបន្ទោស ថាទិញថ្លៃពេក ដ្បិតខ្ញុំបាទមិនចេះតថ្លៃទិញត្រីទេ ទានប្រោស ។
- នារី៖មិនអីទេ ទៅសួរទិញចុះចាំខ្ញុំតថ្លៃឲ្យ។
- ចិត្រ៖ សុំឲ្យយុនតថ្លៃទិញខ្លួនឯងចុះ។
- នារី៖ នេះពិតជាគាត់ឯង មិនព្រមធ្វើតាមបង្គាប់យើងទេឬ ?
- ចិត្រ៖ ឱ ! យុនបង្គាប់ខ្ញុំបាទបានជានិច្ច ប៉ុន្តែមិនមែនបង្គាប់ឲ្យកាន់កញ្ជ្រែងដើរទិញត្រី ទេ។
- នារី៖ ម៉េច ? គ្រាន់តែឲ្យទិញត្រីរ៉ស់ពីរបីប៉ុណ្ណឹង តើវាខូចកិត្តិយសប៉ុណ្ណាទៅ ?
- ចិត្រ៖ មិនមែនខូចកិត្តិយសអ្វីទេ ប៉ុន្តែមុខក្រសួងទិញត្រីខ្ញុំបាទមិនធ្លាប់ធ្វើ ។

នាងនារីក្ដៅក្រហាយឡើងមុខក្រហម តែមិនមានអំណាចបង្គាប់ឲ្យគេធ្វើតាមបាន ក៏ដើររ៉ុយទៅ ទិញដោយខ្លួនឯង ឯថៅចិត្រក៏កាន់កញ្ជ្រែងដើរតាមក្រោយ កាលទិញបានត្រីរ៉ស់ពីរ ដើរវិល ទៅទិញរានឯទៀតៗ នាងនៅខឹងខ្នាញ់នឹងការចចេសរឹងរូសរបស់ថៅចិត្រណាស់ ក៏ក្លែងដើរ ទិញពីរានមួយទៅរានមួយទៀត ដើររីរក់ចុះឡើងជាច្រើនបក ច្រើនសា ទិញអីវ៉ាន់ច្រើនស្អេក ស្កះទាល់តែថៅចិត្រយកទៅស្ទើរតែមិនរួច នាងនឹកខ្នាញ់ក៏ខ្នាញ់ណាស់ តែនឹកចង់សើចក៏ចង់ សើចណាស់ ដោយបានឃើញថៅចិត្រកាន់ពេញដៃទាំងពីរ យួរផង គៀ្រតគ្លៀកផង រណែង រណោង ហើយនាងធ្វើជាដើរវិលជាច្រើនបកច្រើនត្រឡប់ ទើបបត់ចូលទៅឯរថយន្ត ។ ឯថៅ

ចិត្រក៏ចេះតែដើរប្រកិតតាមក្រោយដរាបដល់រថយន្ត ហើយទំលាក់អីវ៉ាន់គ្រាំងទៅក្នុងរថយន្ត ។ នាងនារីឃើញកិរិយាថៅចិត្រធ្វើដូច្នោះ ក៏ច្រឡោតឡើងថា៖

- យី ! គាត់នេះ ក្លែងទំលាក់អីវ៉ាន់លើក្បាលអញឬ ?
- ថៅចិត្រឆ្លើយឡើងថា៖ សូមអត់ទោសទានប្រោស ធូន់ពេក តែខ្ញុំបាទទម្លាក់លើក្តាររថយន្តទេតើ។
- នារី៖ ប្រយ័ត្នគាត់ឯង កុំប្រើកិរិយាថោកទាបពេក ។

នាយចិត្រឮហើយគ្រាន់តែញញឹមហុិះៗ ហាក់ដូចជាមិនយកចិត្តទុកដាក់នឹងការខឹងសម្បារបស់ថៅហ្វាយក្រមុំនោះសោះ ។ អ្នកទាំងពីរក៏អង្គុយនៅស្ងៀមៗទាំងអស់គ្នា ឥតនិយាយគ្នាមួយម៉ាត់សោះ មួយស្របក់ទើបឃើញហ្លួងរតនសម្បត្តិ មកដល់ទីចតរថយន្ត ជាមួយនឹងបុរសកម្លោះមួយនាក់ មុខវែងពាក់មួកស ពាក់អាវបើកក ចងក្រវាត់ ស្លៀកខោខ្លី ពាក់ស្បែកជើងពណ៌ក្រហមស្រោមជើងស ។ នាយចិត្រគ្រាន់តែក្រឡេកមើលទៅឃើញបុរសនោះ ក៏មានសេចក្តីទាស់ចិត្ត ឥតត្រេកអរបន្តិចបន្តួចឡើយ។

ហ្លួងរតនសម្បត្តិនិយាយថា៖

- យើងគោងប្រញាប់ទៅឥឡូវទើបបាន បង្អង់យូរពេកមិនបានទេ ដ្បិតយើងឥតដាក់កាំភ្លើងមកផងសោះ ក្រែងចោរប្លន់កណ្តាលផ្លូវ។

នាងនារីបែរទៅញញឹមយ៉ាងផ្អែម ខណៈដែលបុរសកម្លោះនោះឡើងមកលើរថហើយសួរថា៖

- លោកបាឡាត់ដាក់កាំភ្លើងមកដែរឬទេ !

ថៅចិត្រត្អូញរង៉ូវនៅតែក្នុងបំពង់ក **បុរសកម្លោះនេះឬជាបាឡាត់ស្រុកៗសង្កែ រូបរាងបែបនេះមិនគួរសេពគប់សោះឡើយ កន្លែងអង្គុយវាលល្វឹងមិនអង្គុយ នៅតែទៅប្រជ្រៀតអង្គុយក្បែរយុននារីក្រអឺត** !

ចំណែកខាងលោកបាឡាត់ទះគូទហើយប្រាប់ហើយ៖

- យុនកុំព្រួយមានកាំភ្លើងខ្លីជាប់មកមួយដែរ។

ហ្លួងរតនសម្បត្តិក៏សើចហើយថា៖

- រថយន្តទៅវេលានេះ ប្រហែលជាម៉ោង៩រសៀល ទើបដល់ទៅផ្ទះយើង។

ចៅចិត្រក៏ចុះទៅវៃតាមបង្គាប់ ហើយឡើងបររថយន្តចេញទៅ សំដៅទៅតាមផ្លូវបប៉ៃលិន សឹងដេរដាសទៅដោយស្រែចម្ការច្បារដំណាំ លុះផុតពីភូមិភ្នំសំពៅ ភូមិស្ទឹងកាលណា មានតែព្រៃព្រឹក្សាលតារល្លិនិងភ្នំក្រំថ្មដេរដាស ផ្លូវក៏កាន់តែលំបាកឡើងផ្ទៃផែនដីខ្ពស់ៗទាបៗ បត់បែនជាច្រើនជាន់ កាលចៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញបាឡាត់ស្រុកនោះ និយាយក្អាកក្អាយសប្បាយរីករាយជាមួយនឹងនាងនារី ចៅចិត្រក៏កើតមោហាខ្លាំងឡើង ថែមលើសេចក្តីម៉ូម៉ៅកាលដែលទៅផ្សារទិញត្រីនោះមួយជាន់ទៀត ទើបក្លែងកាច់ចង្កូតឲ្យបត់ក្បាលធ្លាក់ទៅជង្ហុករាក់ៗ មួយអន្លើនៅក្បែរផ្លូវ ម៉ាស៊ីនរោទ៍រំពងព្រៃ ហើយទច់ង៉ក់ស្ងៀមនៅនឹងកន្លែងនោះឯង ។

ចៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញភ្នែកគ្រប់ៗគូ សំឡឹងមើលមកចំខ្លួន ។ បាឡាត់ស្រុកភ្លាត់ធ្លាក់ពីទីអង្គុយ ហ្លួងរតនសម្បត្តិកំពុងយកដៃស្ទាបក្បាល ដែលប៉ះទង្គិចនឹងដំបូលរថ នាងនារីផ្អៀងទ្រេតរិះតែធ្លាក់ តែចួនជាចាប់បង្អែកទាន់បាន ។ លោក បាឡាត់បន្ទោសៈ

- សូហ្វ័រចង្រៃបររថអីយ៉ាងអីចេះ។

នាងនារីងាកដម្រង់ខ្លួនហើយបន្ទោសថាៈ

- ចិត្រ គាត់ឯងមិនចេះបរឡានទេឬអី ?

ចៅចិត្រឆ្លើយភ្លាមថាៈ

- បើមិនចេះបរ គង់មិនបានមកដល់ទីនេះទេ។
- ចិត្រ កុំភ្លាហានពេកប្រយ័ត្នពាក្យសំដីបន្តិច។

ហ្លួងរតនសម្បត្តិនិយាយដាស់តឿនចៅចិត្រ ។

ចៅចិត្របែរទៅលោកហ្លួងហើយជំរាបថាៈ

- សូមអត់ទោស ទានប្រោស ប្រសិនបើខ្ញុំបាទមិនកាច់ចង្កូតឲ្យងាកទៅជង្ហុកទេ កង់មុខខាងស្តាំមុខជាប៉ះនឹងដង្កត់នោះជាប្រាកដ ហើយធ្វើឲ្យខូចពេលយូរជាងធ្លាក់ជង្ហុកនេះទៅទៀត។

លោកហ្លួងញាក់មុខទទួលទំនងជាយល់ដូច្នេះដែរ ហើយថៅចិត្របែរមកមើលខាងក្រោយ ក៏ប្រទះនឹងភ្នែកដែលសំឡឹងសំឡក់ដាក់ជាច្រើនដងច្រើនគ្រា ច្រើនគ្រឡប់ ។

រថក៏បរតទៅទៀតដូចធម្មតា តែនាងនារីសង្កេតយល់ដឹងដល់ចិត្តគំនិតរបស់ថៅចិត្រ តែកាលណានាងធ្វើស្និទ្ធស្នាលនឹងបាឡាត់ស្រុកនោះ រថក៏គ្រលែងឃ្លេងឃ្លោង រកកល់ធ្លាក់ជង្ហុកឬដើរខុសផ្លូវទៅ ស្ទើរតែមិនហ៊ាននិយាយអ្វីនឹងលោកបាឡាត់ទៀត ។ តាំងពីនោះមកនាងក៏ដឹងខ្លួនថា ថៅចិត្រមានបំណងអ្វីក្នុងខ្លួននាង ?

លុះរថយន្តបរផុតភូមិព្រៃផ្តៅទៅឆ្ងាយបន្តិច ក៏ទច់ង៉ក់រលត់ម៉ាស៊ីន ទើបថៅចិត្រលោតចុះទៅបើកគ្រឿងម៉ាស៊ីនមើល ស្រាប់តែធ្វើមាត់វៀចក្រងៃវ ។ អ្នកជិះទាំងអស់គ្រប់ៗគ្នា មានសេចក្តីព្រួយជាច្រើន ទើបហ្លួងរតនសម្បត្តិដែលមានសេចក្តីព្រួយច្រើនជាងគេ ក៏ចុះពីរថទៅសួរថៅចិត្រថា៖

- ម៉េចទៅ ទៅទៀតបានឬទេ ? ល្មមកែកុនបានឬទេ ?

ថៅចិត្រគ្រវីក្បាលដោយអស់សង្ឃឹម ហើយជំរាបទៅលោកហ្លួងថា៖

- ទានប្រោស បរទៅទៀតមិនបានទេ វាខូចត្រង់កន្លែងសំខាន់ដែលខ្ញុំបាទធ្វើមិនកើត តោងទៅជួលចិនក្រឡឹងដាក់ជាថ្មីទើបបាន !
- នារីះម្តងនេះស្រេច។

ហើយនាងផ្តេកខ្លួនលើរថយន្តដោយអាការអស់កម្លាំងជាច្រើន។

លោក បាឡាត់ចុះពីរថដើរមកឈរ ចំពីមុខថៅចិត្រហើយថា៖

- គាត់ឯងបររថយ៉ាងម៉េចហ្នឹង ទាល់តែរថខូចអស់ !

ថៅចិត្រឆ្លើយខ្លីៗថា៖

- ខ្ញុំបាទបរដូចយ៉ាងមនុស្សធម្មតា លោកក៏បានឃើញនឹងភ្នែកស្រាប់ហើយ។

លោក បាឡាត់ ខាំមាត់ហើយថា៖

- បើគាត់ឯងមិនបរឲ្យធ្លាក់ជង្ហុកអម្បាញ់មិញ ក៏គង់មិនខូចដល់ម្លឹងដែរ !
- ចិត្រ៖ ចុះលោកគិតថា ខ្ញុំបាទក្លែងបរឲ្យធ្លាក់ជង្ហុកឬអី ?
- បាឡាត់៖ ផ្លូវមានគគាច ម៉េចក៏គាត់ឯងមិនបរឲ្យត្រង់ទៅតាមផ្លូវ មានតែគាត់ឯងក្លែងធ្វើឲ្យធ្លាក់ជង្ហុក ?
- ចិត្រ៖ លោកថាដូចម្ដេចក៏បាន តែខ្ញុំបាទមិនបានក្លែងធ្វើឲ្យវាធ្លាក់ជង្ហុកទេ។
- បាឡាត់៖ គោងប្រយ័ត្នសំដីបន្តិចគាត់ឯង។
- ចិត្រ៖ ខ្ញុំបាទបាននិយាយដោយសំដីគួរសមណាស់ហើយទានប្រោស។
- បាឡាត់៖ ម៉េចក៏គាត់ឯងព្រហើនម្ល៉េះ ក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេទេឬ ?

ថៅចិត្រសើចចំអកបន្តិចហើយថា៖

- ខ្ញុំបាទជាអ្នកស៊ីឈ្នួលគេមែន តែមិនមែនស៊ីឈ្នួលលោក បាឡាត់ទេ។

ហ្លួងរតនសម្បត្តិនឹករំខាន នឹងសំដីនិយាយជជែកគ្នានោះ ក៏ហាមប្រាមទៅថា៖

- ឈប់និយាយប៉ុណ្ណឹងហើយ លោក បាឡាត់ ការនិយាយជជែកគ្នានៅគ្រានេះ វាមិនមានប្រយោជន៍អ្វីឡើយ បុរាណលោកថា **សាបមួយដៃ ប្រៃមួយចឹប** មែនទេ ?
- នារី៖ ចុះយើងគិតធ្វើដូចម្ដេច ទើបទៅដល់ផ្ទះ ?

នាងសួរដោយសេចក្ដីព្រួយបារម្ភជាច្រើន ។

- ហ្លួង៖ ហ្នឹងហើយ ប៉ាក៏មិនដឹងជាគិតធ្វើដូចម្ដេចដែរ សួរថៅចិត្រមើល តើគេគិតធ្វើដូចម្ដេច ?

នាងងាកមកថៅចិត្រសួរថា៖

- ចិត្រ យើងត្រូវធ្វើដូចម្ដេចទើបទៅដល់ផ្ទះ ?
- ចិត្រ៖ ទានប្រោស គោងតែដើរទៅទើបបាន។

តបកំបុតៗធ្វើឲ្យនាងនារីឡើងមុខក្រហម ។

ថៅចិត្រដើរចូលទៅរកហ្លួងរតនសម្បត្តិ ហើយនិយាយជំរាបថា៖

- យើងតោងរង់ចាំនៅទីនេះ ទំរាំមានរថយន្តណាមួយមកដល់ទីនេះ ប្រសិនបើគ្មានទេ ក៏តោងតែស្នាក់នៅទីនេះមួយយប់ បើនឹងដើរជើងទៅក្រែងតែពាក់កណ្ដាលអធ្រាត្រទើបដល់ផ្ទះ។

លោក ហ្លួងដកដង្ហើមធំ នាងនារីសួរទៅលោកឪពុកដោយសេចក្ដីវិតក្កថា៖

- យើងតោងតែដេកស្នាក់ក្នុងព្រៃនេះមួយយប់ទៅឬប៉ា ?

លោក ហ្លួងញាក់មុខហើយថា៖

- កូនឃើញទេ វេលានេះម៉ោង៩ រសៀលហើយ ឬមួយកូនចង់ដើរលមើលក៏តាមចិត្ត ?

នាងនារីគ្រវីក្បាលហើយថា៖

- ទេ ប៉ា ទម្រាំដើរទៅដល់ កូនមុខជាស្លាប់ពាក់កណ្ដាលផ្លូវមិនខានឡើយ។

ថៅចិត្រសើចឡើងទាល់តែនាងនារីបែរទៅសំឡឹងចំមុខ ហើយសួរថា៖

- គាត់ឯងសើចអី !

ថៅចិត្រញញឹមញញែមតាមធម្មតាហើយថា៖

- ខ្ញុំបាទសើចនឹងកំប្រុកមួយនោះទេតើ វាហាក់លោតពីដើមស្រម៉ទៅដើមកន្ទួតព្រៃ វាភ្លាត់ចំណាប់ ធ្លាក់មកដល់ដីជិតប្រកាច់ បានជាខ្ញុំបាទសើចនឹងវា !
- នារី ៖ គេភ័យ គេព្រួយរាល់គ្នាឯងគិតតែពីសើចសប្បាយ។
- ចិត្រ ៖ បានជាខ្ញុំបាទសើច ពីព្រោះសត្វនោះមានជើងដល់ទៅបួន នៅតែមានភ្លាត់ចំណាប់ធ្លាក់ដល់ដីទាល់តែបានដូច្នេះទេតើ !

នាងមិនឆ្លើយតបទៅ គ្រាន់តែសំឡឹងសំឡក់ចុងភ្នែកកន្ទុយភ្នែកប៉ុណ្ណោះ ដោយសារសេចក្ដីមួម៉ៅក្ដៅក្រហាយ ប៉ុន្តែនាងធ្លាប់សំដែងកិរិយាដូច្នេះជានិច្ច ។ ថៅចិត្រថ្មឹកនឹងនិស្ស័យបែបនេះ

មកច្រើនគ្រាហើយ ទើបមិនមានចិត្តព្រួយបារម្ភអ្វី ថែមទាំងយល់ថា ស្ត្រីបើមិនសំដែងកិរិយាងក្ងិកក្ងក់ខ្លះទេ ក៏មិនល្អមើលដែរ គ្រាន់តែកុំឲ្យជ្រុលហួសពេកប៉ុណ្ណោះ ។

ឯនាងនារីនឹកប្រារព្ធនឹងខ្លួនឯងថា កូនឈ្នួលកម្លោះនេះចំឡែកជាងកូនឈ្នួលដទៃៗទៀត ជាអ្នកមានអំនួតបន្តិច ថែមទាំងប្រើសំដីមិនចេះក្រែងចិត្តអ្នកណាទេ តែចេះនិយាយសមហេតុសមផល ទើបនាងចូលចិត្តនិយាយ ឬជជែកពីរឿងអ្វីៗលេង នាងធ្លាប់គិតថា នាងគិតដូច្នេះនឹងមានប្រយោជន៍អ្វី ហើយគេជាអ្វីនឹងនាង គេគ្រាន់តែជាកូនឈ្នួលនាងម្នាក់ប៉ុណ្ណោះទេតើ!

លោក បាឡាត់ដើរឆៀងមកក្បែរនាងនារី ហើយសួរថា៖

- ចុះហេតុអី ក៏យុនចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងអាក្មេងកម្លោះនោះម្ល៉េះ ?
- នារី៖ នរណា ប្រាប់លោកថា ខ្ញុំចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងវា !
- បាឡាត់៖ ខ្ញុំបានឃើញនឹងភ្នែក បានឃើញវានិយាយជជែកនឹងយុន ទាល់តែយុនទាល់ច្រករបស់វា ម្លឹងៗនៅតែយុនទៅនិយាយជជែកនឹងវាទៀត វាជាក្មេងព្រហើនមិនចេះគួរសមទេ យុនពិនិត្យមើលវាឲ្យមែនទែនចុះ។

នាងនារីញាក់មុខទំនងជាយល់ដូច្នោះដែរ ហើយឆ្លើយថា៖

- ចា៎ះ កម្មករនេះឫកពាព្រហើនបន្តិចមែន តែឧស្សាហ៍ធ្វើការណាស់។
- លោក បាឡាត់៖ ប្រហែលជាវាទើបមកនៅទេ បានជាពីដើមមកមិនដែលឃើញសោះ។
- នារី៖ ចា៎ះ វាទើបនឹងមកនៅមែន ប្រហែលជាងពីរខែប៉ុណ្ណឹង ឪពុករបស់ខ្ញុំគាត់មានចិត្តអាណិតមេត្តាដោយឃើញថា ជាមនុស្សកំព្រាឪពុកម្ដាយ ហើយបានប្រគល់ឲ្យជីកអណ្ដូងត្បូងនៅទិសខាងកើត ដែលទើបនឹងបើកថ្មី។

និយាយគ្នាបានត្រឹមប៉ុណ្ណេះ ក៏ស្រាប់តែឮសំឡេងហ្លួងរតនសម្បត្តិ ស្រែកហៅនាងនារី ហើយប្រាប់ថា៖

- នារីកូន ចាត់ចែងដាំបាយទឹកទៅ ឪពុកនឹកឃ្លានបាយណាស់ហើយ ឲ្យចៅចិត្រជួយរកឧសភ្លើងផង។

ចៅចិត្រចូលមកជិតហើយសួរថា៖

- យុននឹងឲ្យខ្ញុំបាទជួយធ្វើការអ្វីខ្លះ ចូរប្រាប់មកចុះ ?

- នារី៖ ទៅរកដុំថ្មបីដុំមក ហើយរកឧសបង្កាត់ភ្លើងឡើងផង។

នាងបង្គាប់ទៅលោក បាឡាត់ថា៖

- លោក បាឡាត់អាណិតយកសាច់ដាក់កំប៉ុងមកឲ្យខ្ញុំពីរកំប៉ុង និងសណ្តែកហាឡាន់តៅផង។

កម្លោះទាំងពីរនាក់ ក៏ខំធ្វើការផ្តាប់ផ្គុននាងក្រមុំយ៉ាងម៉ឺងម៉ាត់ ឯថៅចិត្របានដុំថ្មតូចៗបីដុំ ហើយដាក់តំរៀបជាមុំជើងក្រាន ហើយទៅរកកាច់ឧសមកបង្កាត់ភ្លើងឆេះថ្កោលឡើង ។

- យុននឹងឲ្យខ្ញុំបាទធ្វើអីទៀត។

ថៅចិត្រសួរនាងខណៈដែលបង្កាត់ភ្លើងរួចហើយ ។

- នារី៖ ចៀនត្រីឆាសាច់គោ នឹងសណ្តែកទ្រើង អើ ! យើងគ្មានខ្ទះទេ ថៅចិត្រតោងទៅរកខ្ទះមក។
- ចិត្រ៖ អេ ទានប្រោស ទីនេះមិនមែនផ្សារសង្កែទេ ចុះឲ្យខ្ញុំទៅរកខ្ទះឯណាមកជូនយុនបាន ?

នាងដកដង្ហើមធំហើយប្រាប់ថា៖

- អើ នេះប្រុសត្រលាំង ម្តេចក៏មិនយល់ការអ្វីសោះ ខ្ញុំគ្រាន់តែឲ្យទៅរកភាជន៍អ្វីមួយសំប៉ែតៗ ក៏បានហើយ សំរាប់យកមកចៀនឆាប៉ុណ្ណោះ។

ថៅចិត្រញញឹមហើយថា៖

- ប៉ុណ្ណឹងទេឬ ?

ហើយស្ទុះក្រោកទៅឯរថយន្ត លើកពូកកម្រាលអង្គុយឡើងមើលឃើញចានស្ពាន់សសំប៉ែតៗកាន់លើកបង្ហាញទៅនាងនារីថា៖

- បែបនេះបានឬទេ ?

តាំងអំពីថៅចិត្រចូលមកនៅជ្រកកោននឹងនាងនារី នាងមិនដែលញញឹមម្ដងសោះ ទើបតែមកពេលនេះ នាងក៏ញញឹមជំនួសពាក្យតបជាគ្រាដំបូង ។

លុះលាងចានស្ពាន់រួចហើយ ថៅចិត្រក៏ដាក់លើជើងក្រានបណ្ដោះអាសន្ននោះឯង ។

នារីក៏យកខ្លាញ់ជ្រូកដាក់ចៀនក្នុងចាននោះ ថៅចិត្រក៏យកស្លឹកត្នោតបក់ភ្លើងឲ្យឆេះឡើងទាល់តែផែះហុយទ្រុបឡើង ទាល់តែនាងប្រាប់ឲ្យឈប់បក់ ។

- ចិត្រ៖ ហ្នឹងយុនគិតពិសាតែសាច់ទទេ មិនដាំបាយទេឬ ?

ថៅចិត្រសួរនាងដោយហេតុមិនឃើញនាងដាំបាយសោះ ។

- នារី៖ អើមែនហើយ ចិត្រ ខ្ញុំភ្លេចឈឹង ចុះយើងរកឆ្នាំងឯណាដាំបាយហ៎ះ ?

នាងនិយាយហើយសំឡឹងមុខថៅចិត្រ ទំនងសូមឲ្យជួយគិតគូរផង ។

ថៅចិត្រដឹងទំនង ក៏រត់ទៅឯរថយន្តម្ដងទៀត រកបានកំប៉ុងបៀរមួយធំ បើកដួសយកសាច់បៀរចេញខ្ចប់អស់ ហើយក៏វិលមករកនារីសួរថា៖

- បែបនេះប្រើបានទេ យុន ?

នាងនារីញញឹមទទួលម្ដងទៀត ម្ដងនេះញញឹមចេញមកដោយចិត្តសុចរិតឥតក្លែងបន្តិចឡើយ គ្រានេះដែលថៅចិត្រឃើញថា នារីថៅហ្វាយក្រមុំរបស់គេនេះ មានកិរិយាទន់ភ្លន់ផ្អែមល្ហែមចំឡែកណាស់ !

- នារី ៖ ប្រហែលជាប្រើការបាន ចិត្រ។

នាងតបទៅដោយសំដីធម្មតា ។

- នារី៖ អើ ! ចុះយើងបានទឹកពីណាមកដាំបាយហ៎ះ ?
- ចិត្រ ៖ មិនអីទេ ទុកភ្នាក់ងារខ្ញុំបាទរកជូនយុនទាល់តែបាន។

ថាហើយក៏ទៅបើកបំពង់ទឹកក្នុងរថយន្ត ទឹកក៏ហូរចេញមកទាល់តែពេញកំប៉ុង ហើយយកមកឲ្យនាងនារី ។

លោក ហ្លួង លាន់សំដីពីក្នុងរថយន្តមកថា៖

- ឆ្លាតគ្រាន់បើ បើមិនបានថៅចិត្រ ប្រហែលជាអត់បាយក្នុងពេលនេះទាំងអស់គ្នាមិនខាន។

ឯលោក បាឡាត់ទទួលយកអាសាជាអ្នកដាំបាយ ដោយដឹងខ្លួនថា ខ្លួនដូចជាចាញ់ប្រៀបថៅចិត្រច្រើនណាស់ ការដែលនៅស្ងៀមមិនជួយខ្វល់ខ្វាយនឹងគេ ស្រាប់តែបាយឆ្អិនបរិភោគនោះដូចជាមិនទំនងសោះ !

ឯថៅចិត្រតអំពីនោះ មិនបានជួយធ្វើអ្វីទៀតទាល់តែដល់បាយឆ្អិន ទើបដួសបាយដាក់ចានដាក់ត្រីចៀន ឆាសាច់គោ យកទៅជូនលោក ហ្លួង ឯខ្លួនឯងនិងនាងនារីបរិភោគនឹងស្លឹកឈើ ឯលោក បាឡាត់ស្រុកបរិភោគនឹងក្រដាសកាសែត ដែលខ្ចប់អីវ៉ាន់មកពីផ្សារសង្កែ៕

# រឿងកុលាបប៉ៃលិនវគ្គទី៤

ត្រង់នេះ នាងនារីសង្កេតមើលទឹកមុខថៅចិត្រ ឃើញស្លូតស្រពោនទៅច្រើន ថៅចិត្រសន្សឹមៗ ងើយមុខមើលទៅមុខនាង ហើយនិយាយថា៖

- ប្រសិនបើធៀបខ្លួនយុនជាខ្ញុំបាទវិញ ហើយថែមទាំងជាស្ត្រីផង យុនគោងគិតថា ការតស៊ូនឹងជីវិតដែលក្រីក្រលំបាកតោកយ៉ាកទៅតាមទំនើងតែម្នាក់ឯង នុះ តើវាមានរសជាតិដូចម្ដេចខ្លះ ? តែខ្ញុំបាទជាប្រុសល្មមអត់ធ្មត់សេចក្ដីលំបាកបានគ្រប់ៗយ៉ាង ហើយធ្លាប់តទល់នឹងសេចក្ដីក្រីក្រតោកយ៉ាកមកច្រើនហើយ ចួនកាលខ្ញុំបាទអត់បាយពេញ១ថ្ងៃក៏មាន។

នាងនារីអង្គុយសំងំស្ងៀមចាំស្ដាប់ថៅចិត្រនិយាយ តែក្នុងចិត្តនឹកអាណិតអាសូរថៅចិត្រជាពន្លឹកហើយនឹកដល់ខ្លួនឯង ថា បើអញត្រូវបានទទួលគ្រោះថ្នាក់យ៉ាងនេះផង តើនឹងមានសេចក្ដីលំបាកយ៉ាងណាទៅ !

- នារី៖ ចុះចិត្រមកនៅទីនេះ បានស្រួលខ្លះហើយឬនៅឡើយទេ ?

នាងនិយាយតិចៗហើយមានសំឡេងទន់ជាងមុនច្រើន ។

ថៅចិត្រសំឡឹងមើលភ្នែកនាងនារី ហើយញញឹមយ៉ាងរោះរាយឆ្លើយថា៖

- ខ្ញុំបាទបានស្រួលច្រើន ! យុននារី តាំងអំពីខ្ញុំបាទចូលមកអាស្រ័យនៅក្នុងផ្ទះយុននេះ ស្រួលចិត្តឡើងច្រើន មិនបាច់នឹកព្រួយក្រែងអត់បាយស្លាប់ បើបប៉ៃលិននៅតែមានមេត្តាខ្ញុំបាទយ៉ាងនេះជានិច្ចទៅ ខ្ញុំបាទមុខជាសូមធ្វើឆ្អឹងនៅដំបន់នេះជាប្រាកដ !

អាកាសនៅបប៉ៃលិន តាមធម្មតាត្រជាក់ជាងស្រុកសង្កែបាត់ដំបងច្រើន បើចួនជាត្រូវរដូវរងាដូចក្នុងវេលានោះ ក៏កាន់តែត្រជាក់ខ្លាំងឡើងទៀតជាច្រើន លុះព្រលួរទឹកសន្សើមស្រក់ចុះពីស្លឹកឈើមិនដាច់រយៈ ដួងចន្ទ្រមួយចំហៀងនោះក៏លិចបាត់បាំងដងភ្នំទៅ ខ្យល់ត្រជាក់ក៏កាន់តែបក់ផាត់ខ្លាំងឡើង ជាហេតុនាំឲ្យត្រជាក់ញាក់ដល់បេះដូងកម្លោះក្រមុំទាំងពីរនាក់។ ទើបថៅចិត្រសន្សឹមក្រោកឡើងមើលទៅផ្ទៃមេឃដោយកិរិយាស្រពោនស្រពន់ ហើយនិយាយឡើងថា៖

- យប់ជ្រៅហើយ យុននារី អញ្ជើញឡើងទៅផ្ទះវិញចុះ អំណាចទឹកសន្សើមនិងខ្យល់រងា បែបនេះ អាចធ្វើឲ្យយុនផ្តាសាយ ឬទៅជាគ្រុនក៏សឹងបាន !

ឯនាងនារីក្រោកដើរឡើងទៅលើផ្ទះដោយស្រួល ដូចកូនក្មេងដែលប្រដៅបានបែបបទល្អ តែនាងមកនឹកឆ្ងល់ក្នុងចិត្តថា៖

- កម្មករកម្លោះនេះ មានអំណាចអ្វីហ្ន៎ ! អាចហ៊ានបង្គាប់អញឲ្យធ្វើតាមបង្គាប់ខ្លួនបាន ដោយងាយដូច្នេះ។

តែនាងក៏គិតយល់ថា៖

- ប្រសិនបើអញនៅហាលសន្សើមយូរពេកអាចធ្វើឲ្យគ្រុនរងា ឬផ្តាសាយបានមែន ។

លុះដល់ព្រឹកឡើង ចៅចិត្រក៏លីចបដើរចេញទៅធ្វើការជីកត្បូងនាអណ្តូងត្បូង ត្រង់ទិសខាងកើតដូចសព្វដង ដែលធ្លាប់ធ្វើមករាល់ៗថ្ងៃ បានដើរកាត់មុខផ្ទះធំនោះទៅ ស្រាប់តែឃើញនាងនារី និងលោក ហ្លួងរតនសម្បត្តិ អង្គុយក្នុងរថយន្ត យីហោ រ៉ឺណូត៍ ដែលជារថយន្តសម្រាប់ប្រើទៅទិញអីវ៉ាន់នៅផ្សារសង្កែ ។ ឯតាសុន ជាអ្នកបររថនោះ ខំប្រឹងវៃទាល់តែបែកញើស ក៏នៅតែមិនឆេះសោះ ដល់យូរពេកណាស់ទើបលោក ហ្លួងស្រែកសួរទៅថា៖

- តាសុន រថយន្តមិនឆេះទេឬ ?

តាសុនគ្រវីក្បាល យកកន្សែងជូតញើសមុខ ហើយជំរាបទៅលោកហ្លួងថា៖

- មិនឆេះទេ ទានប្រោស ! ខ្ញុំបាទបានដោះលាងសំអាតគ្រឿងអំពីយប់មិញនេះឯង ស្រាប់តែព្រឹកឡើងវាគៀចដូច្នេះទៅ !

ចៅចិត្រដើរចូលមកជិត លើកដៃសំពះលោកហ្លួង ហើយជំរាបសួរថា៖

- ទានប្រោស ព្រះតេជព្រះគុណអញ្ជើញទៅឯណា ?

លោក ហ្លួងតបទៅថា៖

- ខ្ញុំទៅទទួលលោក បាឡាត់ស្រុក ឯស្រុកសង្កែបន្តិច តែរថវាមិនព្រមឲ្យទៅសោះ ចៅចិត្រ !

នាងនារីសំឡឹងមើលថៅចិត្រមួយភ្លែត ឃើញទឹកមុខដូចជាស្រស់បស់ជាងសព្វថ្ងៃ មានកិរិយាអង់អាចខុសពីកម្មកររងទៀតៗ ។

- នារីៈ ប៉ា ! យើងទៅមិនរួចទេឬអ្វី ?

នាងសួរដោយសេចក្តីព្រួយ ។

- ចិត្រៈ សុំឲ្យខ្ញុំបាទវវៃមើលបន្តិច ក្រែងលោឆេះឡើងបាន។

ហើយថៅចិត្របើកគ្របបាំងគ្រឿងយន្តពិនិត្យមើលមួយស្របក់ក៏ញញឹម ហើយនិយាយថាៈ

- ទានប្រោស ទាស់ត្រង់ណោះ រវៃម្តងទៀតឆេះជាប្រាកដ ហើយប្រាប់តាសុនឲ្យវវៃម្តងទៀត ។

តាសុនចាប់រវៃម្តងទៀត គ្រឿងយន្តក៏គ្រហឹមគឹកកង មួយរំពេចឡើង អ្នកទាំងអស់គ្នាក៏ញញឹម តាសុនក៏ទៅទះស្មាថៅចិត្រហើយ លាន់មាត់ថាៈ

- ពូកែគ្រាន់បើ អ្នកក្មួយអញ !

លោកហ្លួង ក៏លាន់មាត់ដោយសេចក្តីត្រេកអរ ហើយសួរថៅចិត្រថាៈ

- ថៅចិត្រពូកែមែន រៀនចេះពីណា ប្រសប់លាក់ចំណេះណាស់ ?

ថៅចិត្រនឹកត្រេកអរ បង្អោនខ្លួនជំរាបទៅលោកហ្លួងថាៈ

- ទានប្រោស មិនបានរៀនឯណាទេ គ្រាន់តែធ្លាប់បររថយន្តមកដែរ ក៏ល្មមធ្វើកើតចំពោះតែគ្រឿង ដែលខូចខាតបន្តិចបន្តួចប៉ុណ្ណោះ។

ហើយចាប់ចបលើកលីលើស្មា ។

ឯតាសុន បានឮសំដីថៅចិត្រថា **ធ្លាប់បររថយន្តមកដែរ** ក៏នឹកដល់ប្រពន្ធដែលទើបមកដល់ផ្ទះពីព្រឹកមិញនេះ គាត់មិនទាន់បានសាកសួរអំពីសុខទុក្ខសោះ ស្រាប់តែជាប់រវល់មកបររថយន្តជូនលោកហ្លួងទៅស្រុកសង្កែ ទើបគាត់ជំរាបសុំច្បាប់លោកហ្លួងថាៈ

- ទានប្រោស ថ្ងៃនេះខ្ញុំបាទមានធុរៈ ដ្បិតប្រពន្ធខ្ញុំបាទទើបមកដល់ផ្ទះព្រឹកមិញនេះ ខ្ញុំបាទមិនទាន់បានសាកសួរសុខទុក្ខ វាថាប្រញាប់វិលទៅស្រុកវិញ ក្នុងវេលាថ្ងៃត្រង់នេះផង ដូច្នេះសូមព្រះតេជព្រះគុណមេត្តាឲ្យថៅចិត្របររថយន្តជំនួសខ្ញុំ បាទមួយពេលសិនចុះ។

ហ្លួងរតនៈសម្បត្តិស្ងៀមមួយស្របក់ហើយ បែរទៅសួរថៅចិត្រថា៖

- ចិត្រ ឯងបររថយន្តជំនួសតាសុនមួយថ្ងៃបានទេ ?

ថៅចិត្របែរទៅមើលតាសុន ឃើញសំដែងអាការអង្វរ ទើបថៅចិត្រជំរាបទៅលោកហ្លួងថា៖

- ខ្ញុំបាទបរជូនបាន ទានប្រោស។

តាសុនត្រេកអរណាស់ ស្ទុះទៅចាប់ដៃថៅចិត្រអង្រួនថា៖

- អរគុណអ្នកក្មួយណាស់ សូមអ្នកក្មួយសំឡាញ់ជួយយកតែបុណ្យទៅចុះ ហើយគាត់ងាកមកលើកដៃសំពះលាហ្លួងរតន សម្បត្តិដើរចេញទៅ។

ថៅចិត្រយកគ្រឿងប្រដាប់ធ្វើការទៅទុកស្រេចហើយ ក៏ផ្លាស់សំពត់អាវកម្មករជាអ្នកបររថយន្តឡើងកាន់ចង្កូតបរចេញពីទីនោះទៅ ទំនងជាអ្នកឆ្លាតប៉ិនប្រសប់ដោយមិនមានឧបសគ្គ រវាងពាក់កណ្តាលផ្លូវដរាបដល់ស្រុកសង្កែ ដែលជាទីក្រុងបាត់ដំបង ។ ឪពុកនឹងកូន ក៏ចុះពីរថយន្តដើរសំដៅទៅកាន់ផ្ទះមួយក្បែរសាលាស្រុក ប្រហែលជាកន្លះម៉ោងទើបឃើញនាងនារីចុះពីផ្ទះនោះមក ។

ថៅចិត្រសួរដោយកិរិយា សុភាពថា៖

- ត្រឡប់ទៅឥឡូវឬនៅទេ យុន ?
- នៅទេ នាងតបកំបុតៗហើយថា ចិត្រតោងទៅទិញអីវ៉ាន់ឯផ្សារជាមួយនឹងខ្ញុំឥឡូវ នុះកញ្ច្រែង ចិត្រកាន់យកទៅផងណា។

ថៅចិត្រនឹកភាំងបន្តិច ដ្បិតតាំងអំពីកើតមកមិនដែលកាន់កញ្ច្រែងដើរតាមក្រោយស្រីណាម្តងសោះ តែគ្រានេះត្រូវតែធ្វើតាម ដ្បិតគេជាថៅហ្វាយខ្លួន ឲ្យប្រាក់ខែខ្លួន ទុកជាការធ្វើដូច្នេះនាំឲ្យ

អាម៉ាស់មុខយ៉ាងណា ក៏ត្រូវតែប្រតិបត្តិតាមបង្គាប់ទៅសិនចុះ ទើបនាយចិត្តស៊ូកាត់កេរ្តិ៍ខ្មាស ចាប់កញ្ច្រែងដើររ៉ុយតាមក្រោយ ថៅហ្វាយក្រមុំ មានរូបឆោមស្រស់ប្រិមប្រិយនោះទៅ ។

- នារីបង្គាប់៖ ចិត្រ ទៅសួរទិញត្រីរ៉ស់ធំៗ ពីរយកទៅស្ងោរជ្រក់ តើគេលក់មួយថ្លៃប៉ុន្មាន ? រើសឲ្យធាត់ៗបន្តិច ។
- ថៅចិត្រនិយាយសុំខ្លួនថា៖ សូមកុំប្រើឲ្យខ្ញុំបាទទិញឡើយ យុន ! ហើយនិយាយតទៅទៀតថា៖ តាំងពីខ្ញុំបាទកើតមក ខ្ញុំបាទមិនដែលទិញត្រីសាច់ ឬ បន្លែបង្ការអ្វីទេ ក្រែងយុនបន្ទោស ថាទិញថ្លៃពេក ដ្បិតខ្ញុំបាទមិនចេះតថ្លៃទិញត្រីទេ ទានប្រោស ។
- នារី៖មិនអីទេ ទៅសួរទិញចុះចាំខ្ញុំតថ្លៃឲ្យ។
- ចិត្រ៖ សុំឲ្យយុនតថ្លៃទិញខ្លួនឯងចុះ។
- នារី៖ នេះពិតជាគាត់ឯង មិនព្រមធ្វើតាមបង្គាប់យើងទេឬ ?
- ចិត្រ៖ ឱ ! យុនបង្គាប់ខ្ញុំបាទបានជានិច្ច ប៉ុន្តែមិនមែនបង្គាប់ឲ្យកាន់កញ្ច្រែងដើរទិញត្រីទេ។
- នារី៖ ម៉េច ? គ្រាន់តែឲ្យទិញត្រីរ៉ស់ពីរបីប៉ុណ្ណឹង តើវាខូចកិត្តិយសប៉ុណ្ណាទៅ ?
- ចិត្រ៖ មិនមែនខូចកិត្តិយសអ្វីទេ ប៉ុន្តែមុខក្រសួងទិញត្រីខ្ញុំបាទមិនធ្លាប់ធ្វើ ។

នាងនារីក្តៅក្រហាយឡើងមុខក្រហម តែមិនមានអំណាចបង្គាប់ឲ្យគេធ្វើតាមបាន ក៏ដើររ៉ុយទៅទិញដោយខ្លួនឯង ឯថៅចិត្រក៏កាន់កញ្ច្រែងដើរតាមក្រោយ កាលទិញបានត្រីរ៉ស់ពីរ ដើរវិលទៅទិញរានឯទៀតៗ នាងនៅខឹងខ្នាញ់នឹងការចចេសរឹងរូសរបស់ថៅចិត្រណាស់ ក៏ក្លែងដើរទិញពីរានមួយទៅរានមួយទៀត ដើរវីរក់ចុះឡើងជាច្រើនបក ច្រើនសា ទិញអីវ៉ាន់ច្រើនស្អេកស្កះទាល់តែថៅចិត្រយកទៅស្ទើរតែមិនរួច នាងនឹកខ្នាញ់ក៏ខ្នាញ់ណាស់ តែនឹកចង់សើចក៏ចង់សើចណាស់ ដោយបានឃើញថៅចិត្រកាន់ពេញដៃទាំងពីរ យួរផង ត្បៀតក្លៀកផង រណែងរណោង ហើយនាងធ្វើជាដើរវិលជាច្រើនបកច្រើនត្រឡប់ ទើបបត់ចូលទៅឯរថយន្ត ។ ឯថៅចិត្រក៏ចេះតែដើរប្រកិតតាមក្រោយដរាបដល់រថយន្ត ហើយទំលាក់អីវ៉ាន់គ្រាំងទៅក្នុងរថយន្ត ។ នាងនារីឃើញកិរិយាថៅចិត្រធ្វើដូច្នោះ ក៏ច្រឡោតឡើងថា៖

- យី ! គាត់នេះ ក្លែងទំលាក់អីវ៉ាន់លើក្បាលអញឬ ?
- ថៅចិត្រឆ្លើយឡើងថា៖ សូមអត់ទោសទានប្រោស ធ្ងន់ពេក តែខ្ញុំបាទទម្លាក់លើក្តាររថយន្តទេតើ។
- នារី៖ ប្រយ័ត្នគាត់ឯង កុំប្រើកិរិយាថោកទាបពេក ។

នាយចិត្រឮហើយគ្រាន់តែញញឹមហ៊ិះៗ ហាក់ដូចជាមិនយកចិត្តទុកដាក់នឹងការខឹងសម្បារបស់ថៅហ្វាយក្រមុំនោះសោះ ។ អ្នកទាំងពីរក៏អង្គុយនៅស្ងៀមៗទាំងអស់គ្នា ឥតនិយាយគ្នាមួយម៉ាត់សោះ មួយស្របក់ទើបឃើញហ្លួងរតនសម្បត្តិ មកដល់ទីចតរថយន្ត ជាមួយនឹងបុរសកម្លោះមួយនាក់ មុខវែងពាក់មួកស ពាក់អាវបើកក ចងក្រវាត់ ស្លៀកខោខ្លី ពាក់ស្បែកជើងពណ៌ក្រហមស្រោមជើងស ។ នាយចិត្រគ្រាន់តែក្រឡេកមើលទៅឃើញបុរសនោះ ក៏មានសេចក្តីទាស់ចិត្ត ឥតត្រេកអរបន្តិចបន្តួចឡើយ។

ហ្លួងរតនសម្បត្តិនិយាយថា៖

- យើងគោងប្រញាប់ទៅឥឡូវទើបបាន បង្អង់យូរពេកមិនបានទេ ដ្បិតយើងឥតដាក់កាំភ្លើងមកផងសោះ ក្រែងចោរប្លន់កណ្តាលផ្លូវ។

នាងនារីបែរទៅញញឹមយ៉ាងផ្អែម ខណៈដែលបុរសកម្លោះនោះឡើងមកលើរថហើយសួរថា៖

- លោកបាឡាត់ដាក់កាំភ្លើងមកដែរឬទេ !

ថៅចិត្រត្អូញរង៉ូវនៅតែក្នុងបំពង់ក **បុរសកម្លោះនេះឬជាបាឡាត់ស្រុកៗសង្កែ រូបរាងបែបនេះមិនគួរសេពគប់សោះឡើយ កន្លែងអង្គុយវាលល្វឹងមិនអង្គុយ នៅតែទៅប្រជ្រៀតអង្គុយក្បែរយុននារីក្រអឺត** !

ចំណែកខាងលោកបាឡាត់ទះគូទហើយប្រាប់ហើយ៖

- យុនកុំព្រួយមានកាំភ្លើងខ្លីជាប់មកមួយដែរ។

ហ្លួងរតនសម្បត្តិក៏សើចហើយថា៖

- រថយន្តទៅវេលានេះ ប្រហែលជាម៉ោង៩រសៀល ទើបដល់ទៅផ្ទះយើង។

ថៅចិត្រក៏ចុះទៅវៃតាមបង្គាប់ ហើយឡើងបររថយន្តចេញទៅ សំដៅទៅតាមផ្លូវបប៉ៃលិន សឹងដេរដាសទៅដោយស្រែចម្ការច្បារដំណាំ លុះផុតពីភូមិភ្នំសំពៅ ភូមិស្ទឹងកាលណា មានតែព្រៃព្រឹក្សាលតាវល្លិនិងភ្នំក្រំថ្មដេរដាស ផ្លូវក៏កាន់តែលំបាកឡើងផ្ទៃផែនដីខ្ពស់ៗទាបៗ បត់បែនជាច្រើនជាន់ កាលថៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញបាឡាត់ស្រុកនោះ និយាយក្អាកក្អាយសប្បាយរីករាយជាមួយនឹងនាងនារី ថៅចិត្រក៏កើតមោហាខ្លាំងឡើង ថែមលើសេចក្តី

ម៉ូម៉ៅកាលដែលទៅផ្សារទិញត្រីនោះមួយជាន់ទៀត ទើបក្លែងកាច់ចង្កូតឲ្យបត់ក្បាលធ្លាក់ទៅជង្ហុករាក់ៗ មួយអន្លើនៅក្បែរផ្លូវ ម៉ាស៊ីនរោទ៍រំពងព្រៃ ហើយទច់ង៉ក់ស្ងៀមនៅនឹងកន្លែងនោះឯង ។

ថៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញភ្នែកគ្រប់ៗគូ សំឡឹងមើលមកចំខ្លួន ។ បាឡាត់ស្រុកភ្លាត់ធ្លាក់ពីទីអង្គុយ ហ្លួងរតនសម្បត្តិកំពុងយកដៃស្ទាបក្បាល ដែលប៉ះទង្គិចនឹងដំបូលរថ នាងនារីផ្អៀងទ្រេតរិះតែធ្លាក់ តែចួនជាចាប់បង្អែកទាន់បាន ។ លោក បាឡាត់បន្ទោសៈ

- សូហ្វ័រចង្រៃបររថអីយ៉ាងអីចេះ។

នាងនារីងាកដម្រង់ខ្លួនហើយបន្ទោសថាៈ

- ចិត្រ គាត់ឯងមិនចេះបរឡានទេឬអី ?

ថៅចិត្រឆ្លើយភ្លាមថាៈ

- បើមិនចេះបរ គង់មិនបានមកដល់ទីនេះទេ។
- ចិត្រ កុំក្លាហានពេកប្រយ័ត្នពាក្យសំដីបន្តិច។

ហ្លួងរតនសម្បត្តិនិយាយដាស់តឿនថៅចិត្រ ។

ថៅចិត្របែរទៅលោកហ្លួងហើយជំរាបថាៈ

- សូមអត់ទោស ទានប្រោស ប្រសិនបើខ្ញុំបាទមិនកាច់ចង្កូតឲ្យងាកទៅជង្ហុកទេ កង់មុខខាងស្តាំមុខជាប៉ះនឹងដង្កត់នោះជាប្រាកដ ហើយធ្វើឲ្យខូចពេលយូរជាងធ្លាក់ជង្ហុកនេះទៅទៀត។

លោកហ្លួងញាក់មុខទទួលទំនងជាយល់ដូច្នេះដែរ ហើយថៅចិត្របែរមកមើលខាងក្រោយ ក៏ប្រទះនឹងភ្នែកដែលសំឡឹងសំឡក់ដាក់ជាច្រើនដងច្រើនគ្រា ច្រើនគ្រឡប់ ។

រថក៏បរតទៅទៀតដូចធម្មតា តែនាងនារីសង្កេតយល់ដឹងដល់ចិត្តគំនិតរបស់ថៅចិត្រ តែកាលណានាងធ្វើស្និទ្ធស្នាលនឹងបាឡាត់ស្រុកនោះ រថក៏គ្រលែងឃ្លេងឃ្លោង រកកល់ធ្លាក់ជង្ហុកឬដើរ

ខុសផ្លូវទៅ ស្មើរតែមិនហ៊ាននិយាយអ្វីនឹងលោកបាឡាត់ទៀត ។ តាំងពីនោះមកនាងក៏ដឹងខ្លួនថា ចៅចិត្រមានបំណងអ្វីក្នុងខ្លួននាង ?

លុះរថយន្តបរផុតភូមិព្រៃផ្តៅទៅឆ្ងាយបន្តិច ក៏ទច់ង៉ក់រលត់ម៉ាស៊ីន ទើបចៅចិត្រលោតចុះទៅបើកគ្រឿងម៉ាស៊ីនមើល ស្រាប់តែធ្វើមាត់វៀចក្រងែវ ។ អ្នកជិះទាំងអស់គ្រប់ៗគ្នា មានសេចក្តីព្រួយជាច្រើន ទើបហ្លួងរតនសម្បត្តិដែលមានសេចក្តីព្រួយច្រើនជាងគេ ក៏ចុះពីរថទៅសួរចៅចិត្រថា៖

- ម៉េចទៅ ទៅទៀតបានឬទេ ? ល្មមកែកុនបានឬទេ ?

ចៅចិត្រគ្រវីក្បាលដោយអស់សង្ឃឹម ហើយជំរាបទៅលោកហ្លួងថា៖

- ទានប្រោស បរទៅទៀតមិនបានទេ វាខូចត្រង់កន្លែងសំខាន់ដែលខ្ញុំបាទធ្វើមិនកើត តោងទៅជួលចិនក្រឡឹងដាក់ជាថ្មីទើបបាន !
- នារី៖ម្តងនេះស្រេច។

ហើយនាងផ្តេកខ្លួនលើរថយន្តដោយអាការអស់កម្លាំងជាច្រើន។

លោក បាឡាត់ចុះពីរថដើរមកឈរ ចំពីមុខចៅចិត្រហើយថា៖

- គាត់ឯងបររថយ៉ាងម៉េចហ្នឹង ទាល់តែរថខូចអស់ !

ចៅចិត្រឆ្លើយខ្លីៗថា៖

- ខ្ញុំបាទបរដូចយ៉ាងមនុស្សធម្មតា លោកក៏បានឃើញនឹងភ្នែកស្រាប់ហើយ។

លោក បាឡាត់ ខាំមាត់ហើយថា៖

- បើគាត់ឯងមិនបរឲ្យធ្លាក់ជង្ហុកអម្បាញ់មិញ ក៏គង់មិនខូចដល់ម្លឹងដែរ !
- ចិត្រ៖ ចុះលោកគិតថា ខ្ញុំបាទក្លែងបរឲ្យធ្លាក់ជង្ហុកឬអី ?
- បាឡាត់៖ ផ្លូវមានគគាច ម៉េចក៏គាត់ឯងមិនបរឲ្យត្រង់ទៅតាមផ្លូវ មានតែគាត់ឯងក្លែងធ្វើឲ្យធ្លាក់ជង្ហុក ?
- ចិត្រ៖ លោកថាដូចម្តេចក៏បាន តែខ្ញុំបាទមិនបានក្លែងធ្វើឲ្យវាធ្លាក់ជង្ហុកទេ។

- បាឡាត់៖ តោងប្រយ័ត្នសំដីបន្តិចគាត់ឯង។
- ចិត្រ៖ ខ្ញុំបាទបាននិយាយដោយសំដីគួរសមណាស់ហើយទានប្រោស។
- បាឡាត់៖ ម៉េចក៏គាត់ឯងព្រហើនម៉្លេះ ក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេទេឬ ?

ថៅចិត្រសើចចំអកបន្តិចហើយថា៖

- ខ្ញុំបាទជាអ្នកស៊ីឈ្នួលគេមែន តែមិនមែនស៊ីឈ្នួលលោក បាឡាត់ទេ។

ហ្លួងរតនសម្បត្តិនឹករំខាន នឹងសំដីនិយាយជជែកគ្នានោះ ក៏ហាមប្រាមទៅថា៖

- ឈប់និយាយប៉ុណ្ណឹងហើយ លោក បាឡាត់ ការនិយាយជជែកគ្នានៅគ្រានេះ វាមិនមានប្រយោជន៍អ្វីឡើយ បុរាណលោកថា **សាបមួយដៃ ប្រៃមួយចឹប** មែនទេ ?
- នារី៖ ចុះយើងគិតធ្វើដូចម្តេច ទើបទៅដល់ផ្ទះ ?

នាងសួរដោយសេចក្តីព្រួយបារម្ភជាច្រើន ។

- ហ្លួង៖ ហ្នឹងហើយ ប៉ាក៏មិនដឹងជាគិតធ្វើដូចម្តេចដែរ សួរថៅចិត្រមើល តើគេគិតធ្វើដូចម្តេច ?

នាងងាកមកថៅចិត្រសួរថា៖

- ចិត្រ យើងត្រូវធ្វើដូចម្តេចទើបទៅដល់ផ្ទះ ?
- ចិត្រ៖ ទានប្រោស តោងតែដើរទៅទើបបាន។

តបកំបុតៗធ្វើឲ្យនាងនារីឡើងមុខក្រហម ។

ថៅចិត្រដើរចូលទៅរកហ្លួងរតនសម្បត្តិ ហើយនិយាយជំរាបថា៖

- យើងតោងរង់ចាំនៅទីនេះ ទំរាំមានរថយន្តណាមួយមកដល់ទីនេះ ប្រសិនបើគ្មានទេ ក៏តោងតែស្នាក់នៅទីនេះមួយយប់ បើនឹងដើរជើងទៅក្រែងតែពាក់កណ្តាលអធ្រាត្រទើបដល់ផ្ទះ។

លោក ហ្លួងដកដង្ហើមធំ នាងនារីសួរទៅលោកឪពុកដោយសេចក្តីវិតក្កថា៖

- យើងតោងតែដេកស្នាក់ក្នុងព្រៃនេះមួយយប់ទៅឬប៉ា ?

លោក ហ្លួងញាក់មុខហើយថា៖

- កូនឃើញទេ វេលានេះម៉ោង៩ រសៀលហើយ ឬមួយកូនចង់ដើរលមើលក៏តាមចិត្ត ?

នាងនារីគ្រវីក្បាលហើយថា៖

- ទេ ប៉ា ទម្រាំដើរទៅដល់ កូនមុខជាស្លាប់ពាក់កណ្ដាលផ្លូវមិនខានឡើយ។

ថៅចិត្រសើចឡើងទាល់តែនាងនារីបែរទៅសំឡឹងចំមុខ ហើយសួរថា៖

- គាត់ឯងសើចអី !

ថៅចិត្រញញឹមញញែមតាមធម្មតាហើយថា៖

- ខ្ញុំបាទសើចនឹងកំប្រុកមួយនោះទេតើ វាហក់លោតពីដើមស្រម៉ទៅដើមកន្ទួតព្រៃ វាភ្លាត់ចំណាប់ ធ្លាក់មកដល់ដីជិតប្រកាច់ បានជាខ្ញុំបាទសើចនឹងវា !
- នារី ៖ គេភ័យ គេព្រួយរាល់គ្នាឯងគិតតែពីសើចសប្បាយ។
- ចិត្រ ៖ បានជាខ្ញុំបាទសើច ពីព្រោះសត្វនោះមានជើងដល់ទៅបួន នៅតែមានភ្លាត់ចំណាប់ធ្លាក់ដល់ដីទាល់តែបានដូច្នេះទេតើ !

នាងមិនឆ្លើយតបទៅ គ្រាន់តែសំឡឹងសំឡក់ចុងភ្នែកកន្ទុយភ្នែកប៉ុណ្ណោះ ដោយសារសេចក្ដីមួម៉ៅក្ដៅក្រហាយ ប៉ុន្តែនាងធ្លាប់សំដែងកិរិយាដូច្នេះជានិច្ច ។ ថៅចិត្រថ្មឹកនឹងនិស្ស័យបែបនេះមកច្រើនគ្រាហើយ ទើបមិនមានចិត្តព្រួយបារម្ភអ្វី ថែមទាំងយល់ថា ស្ត្រីបើមិនសំដែងកិរិយាងក្ងិកក្ងក់ខ្លះទេ ក៏មិនល្អមើលដែរ គ្រាន់តែកុំឲ្យជ្រុលហួសពេកប៉ុណ្ណោះ ។

ឯនាងនារីនឹកប្រារព្ធនឹងខ្លួនឯងថា កូនឈ្នួលកម្លោះនេះចំឡែកជាងកូនឈ្នួលដទៃៗទៀត ជាអ្នកមានអំនួតបន្តិច ថែមទាំងប្រើសំដីមិនចេះក្រែងចិត្តអ្នកណាទេ តែចេះនិយាយសមហេតុសមផល ទើបនាងចូលចិត្តនិយាយ ឬជជែកពីរឿងអ្វីៗលេង នាងធ្លាប់គិតថា នាងគិតដូច្នេះនឹងមានប្រយោជន៍អ្វី ហើយគេជាអ្វីនឹងនាង គេគ្រាន់តែជាកូនឈ្នួលនាងម្នាក់ប៉ុណ្ណោះទេតើ!

លោក បាឡាត់ដើរឆៀងមកក្បែរនាងនារី ហើយសួរថា៖

- ចុះហេតុអ្វី ក៏យុនចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងអាក្មេងកម្លោះនោះម្ល៉េះ ?
- នារី៖ នរណា ប្រាប់លោកថា ខ្ញុំចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងវា !
- បាឡាត់៖ ខ្ញុំបានឃើញនឹងភ្នែក បានឃើញវានិយាយជជែកនឹងយុន ទាល់តែយុនទាល់ច្រករបស់វា ម្លឹងៗនៅតែយុនទៅនិយាយជជែកនឹងវាទៀត វាជាក្មេងព្រហើនមិនចេះគួរសមទេ យុនពិនិត្យមើលវាឲ្យមែនទែនចុះ។

នាងនារីញាក់មុខទំនងជាយល់ដូច្នោះដែរ ហើយឆ្លើយថា៖

- ចា៎៖ កម្មករនេះឫកពាព្រហើនបន្តិចមែន តែឧស្សាហ៍ធ្វើការណាស់។
- លោក បាឡាត់៖ ប្រហែលជាវាទើបមកនៅទេ បានជាពីដើមមកមិនដែលឃើញសោះ។
- នារី៖ ចា៎៖ វាទើបនឹងមកនៅមែន ប្រហែលជាងពីរខែប៉ុណ្ណឹង ឪពុករបស់ខ្ញុំគាត់មានចិត្តអាណិតមេត្តាដោយឃើញថា ជាមនុស្សកំព្រាឪពុកម្តាយ ហើយបានប្រគល់ឲ្យជីកអណ្តូងត្បូងនៅទិសខាងកើត ដែលទើបនឹងបើកថ្មី។

និយាយគ្នាបានត្រឹមប៉ុណ្ណោះ ក៏ស្រាប់តែឮសំឡេងហ្លួងរតនសម្បត្តិ ស្រែកហៅនាងនារី ហើយប្រាប់ថា៖

- នារីកូន ចាត់ចែងដាំបាយទឹកទៅ ឪពុកនឹកឃ្លានបាយណាស់ហើយ ឲ្យថៅចិត្រជួយរកឧសភ្លើងផង។

ថៅចិត្រចូលមកជិតហើយសួរថា៖

- យុននឹងឲ្យខ្ញុំបាទជួយធ្វើការអ្វីខ្លះ ចូរប្រាប់មកចុះ ?
- នារី៖ ទៅរកដុំថ្មបីដុំមក ហើយរកឧសបង្កាត់ភ្លើងឡើងផង។

នាងបង្គាប់ទៅលោក បាឡាត់ថា៖

- លោក បាឡាត់អាណិតយកសាច់ដាក់កំប៉ុងមកឲ្យខ្ញុំពីរកំប៉ុង និងសណ្តែកហាឡាន់តៅផង។

កម្លោះទាំងពីរនាក់ ក៏ខំធ្វើការផ្គាប់ផ្គុននាងក្រមុំយ៉ាងម៉ឺងម៉ាត់ ឯថៅចិត្របានដុំថ្មតូចៗបីដុំ ហើយដាក់តំរៀបជាមុំជើងក្រាន ហើយទៅរកកាច់ឧសមកបង្កាត់ភ្លើងឆេះថ្គោលឡើង ។

- យុននឹងឲ្យខ្ញុំបាទធ្វើអីទៀត។

ថៅចិត្រសួរនាងខណៈដែលបង្កាត់ភ្លើងរួចហើយ ។

- នារី៖ ចៀនត្រីឆាសាច់គោ នឹងសណ្ដែកទ្រើង អើ ! យើងគ្មានខ្ទះទេ ថៅចិត្រតោងទៅរកខ្ទះមក។
- ចិត្រ៖ អេ ទានប្រោស ទីនេះមិនមែនផ្សារសង្កែទេ ចុះឲ្យខ្ញុំទៅរកខ្ទះឯណាមកជូនយុនបាន ?

នាងដកដង្ហើមធំហើយប្រាប់ថា៖

- អើ នេះប្រុសត្រលាំង ម្ដេចក៏មិនយល់ការអ្វីសោះ ខ្ញុំគ្រាន់តែឲ្យទៅរកភាជន៍អ្វីមួយសំប៉ែតៗ ក៏បានហើយ សំរាប់យកមកចៀនឆាប៉ុណ្ណោះ។

ថៅចិត្រញញឹមហើយថា៖

- ប៉ុណ្ណឹងទេឬ ?

ហើយស្ទុះក្រោកទៅឯរថយន្ត លើកពូកកម្រាលអង្គុយឡើងមើលឃើញចានស្ពាន់សសំប៉ែតៗ កាន់លើកបង្ហាញទៅនាងនារីថា៖

- បែបនេះបានឬទេ ?

តាំងអំពីថៅចិត្រចូលមកនៅជ្រកកោននឹងនាងនារី នាងមិនដែលញញឹមម្ដងសោះ ទើបតែមកពេលនេះ នាងក៏ញញឹមជំនួសពាក្យតបជាគ្រាដំបូង ។

លុះលាងចានស្ពាន់រួចហើយ ថៅចិត្រក៏ដាក់លើជើងក្រានបណ្ដោះអាសន្ននោះឯង ។

នារីក៏យកខ្លាញ់ជ្រូកដាក់ចៀនក្នុងចាននោះ ថៅចិត្រក៏យកស្លឹកត្នោតបក់ភ្លើងឲ្យឆេះឡើង ទាល់តែផែះហុយទ្រុបឡើង ទាល់តែនាងប្រាប់ឲ្យឈប់បក់ ។

- ចិត្រ៖ ហ្នឹងយុនគិតពិសាតែសាច់ទទេ មិនដាំបាយទេឬ ?

ថៅចិត្រសួរនាងដោយហេតុមិនឃើញនាងដាំបាយសោះ ។

- នារី៖ អើមែនហើយ ចិត្រ ខ្ញុំភ្លេចឈឹង ចុះយើងរកឆ្នាំងឯណាដាំបាយហ៎ះ ?

នាងនិយាយហើយសំឡឹងមុខថៅចិត្រ ទំនងសូមឲ្យជួយគិតគូរផង ។

ថៅចិត្រដឹងទំនង ក៏រត់ទៅឯរថយន្តម្តងទៀត រកបានកំប៉ុងបៀរមួយធំ បើកដួសយកសាច់បៀរចេញខ្ចប់អស់ ហើយក៏វិលមករកនារីសួរថា៖

- បែបនេះប្រើបានទេ យុន ?

នាងនារីញញឹមទទួលម្តងទៀត ម្តងនេះញញឹមចេញមកដោយចិត្តសុចរិតឥតក្លែងបន្តិចឡើយ គ្រានេះដែលថៅចិត្រឃើញថា នារីថៅហ្វាយក្រមុំរបស់គេនេះ មានកិរិយាទន់ភ្លន់ផ្អែមល្ហែមចំឡែកណាស់ !

- នារី ៖ ប្រហែលជាប្រើការបាន ចិត្រ។

នាងតបទៅដោយសំដីធម្មតា ។

- នារី៖ អើ ! ចុះយើងបានទឹកពីណាមកដាំបាយហ៎ះ ?
- ចិត្រ ៖ មិនអីទេ ទុកភ្នាក់ងារខ្ញុំបាទរកជូនយុនទាល់តែបាន។

ថាហើយក៏ទៅបើកបំពង់ទឹកក្នុងរថយន្ត ទឹកក៏ហូរចេញមកទាល់តែពេញកំប៉ុង ហើយយកមកឲ្យនាងនារី ។

លោក ហ្លួង លាន់សំដីពីក្នុងរថយន្តមកថា៖

- ឆ្លាតគ្រាន់បើ បើមិនបានថៅចិត្រ ប្រហែលជាអត់បាយក្នុងពេលនេះទាំងអស់គ្នាមិនខាន។

ឯលោក បាឡាត់ទទួលយកអាសាជាអ្នកដាំបាយ ដោយដឹងខ្លួនថា ខ្លួនដូចជាចាញ់ប្រៀបថៅចិត្រច្រើនណាស់ ការដែលនៅស្ងៀមមិនជួយខ្វល់ខ្វាយនឹងគេ ស្រាប់តែបាយឆ្អិនបរិភោគនោះដូចជាមិនទំនងសោះ !

ឯថៅចិត្រតអំពីនោះ មិនបានជួយធ្វើអ្វីទៀតទាល់តែដល់បាយឆ្អិន ទើបដួសបាយដាក់ចាន ដាក់ត្រីចៀន ឆាសាច់គោ យកទៅជូនលោក ហ្លួង ឯខ្លួនឯងនិងនាងនារីបរិភោគនឹងស្លឹកឈើ ឯលោក បាឡាត់ស្រុកបរិភោគនឹងក្រដាសកាសែត ដែលខ្ចប់អីវ៉ាន់មកពីផ្សារសង្កែ៕